00154557

# FILING COVER PAGE

| | | | | | |
|---|---|---|---|---|---|
| **Case Number:** | 002/14-08-2006 | **Case Name:** | | Introductory Submission dated 18 July 2007 | |
| **Document Title:** | Co-Prosecutors' Response to Defence Appeal Against Co-Investigating Judges' Order of the Provisional Detention of KANG Kek Iev alias Duch on 31 July 2007 | | | | |
| **Date Filed:** | 03 Oct 2007 | Language: | English (Original) and Khmer | | |
| **Pages:** | 654 | | Request : Original English (28), Khmer Translation (44), Authorities (477) and Appendices (105) | | |
| **Filed by:** | Mr PAK Chanlino | Position: | Greffier of the OCP | | |
| **Address:** | Room No. 319, ECCC | Email: | Pak.chanlino@eccc.gov.kh | Telephone Number: | Extn: 6037 |
| **List of Appendices:** | | | | | |

**A.** Seth MYDANS, "Khmer Rouge Torturer Converts, Feels His Life is Like That of St Paul", *The Seattle Times,* 2 May 1999.

**B.** Nic Dunlop, *The Lost Executioner: A Story of the Khmer Rouge* (Bloomsbury: 2005), pp. 252-253 & 270-289. *Exceeds 30 pages.*

**C.** Media article by DC-Cam, "Searching for the Truth", Special English Edition, July 2003, page 36 (ERN 00080431).

**D.** The interview with the Office of the UNHCHR on 4-6 June 1999, ERN 00002494-00002557, pp. 1,2,3, 13, 14, 25, 26, 47, 57-59. *Exceeds 30 pages.*

**E.** Nate Thayer in the *Far Eastern Economic Review* May 13, 1999 "Death in Detail" (ERN 00087513-00087514).

**F.** Nate Thayer in the *Far Eastern Economic Review* May 13, 1999, "I am in Danger" (ERN 00087513-00087514).

**G.** Amnesty International's Urgent Action 93/99 "Fear for Safety" 29 April 1999 AI Index ASA 23/08/99.

**H.** Geerteke JANSEN, *Voices of Takeo: A Pilot Fear Assessment with Respect to Possible Witnesses of the Extraordinary Chambers in the Courts of Cambodia* (Phnom Penh: Documentation Center of Cambodia, October 2006), pp. 1-3, 20-33, 38-48. *Exceeds 30 pages.*

**I.** EA Meng-Try and SIM Sorya, *Victims and Perpetrators – Testimony of Young Khmer*

00154558

*Rouge Comrades*, (Phnom Penh: Documentation Center of Cambodia, 2001) (Introductory Submission document number 4.31, ERN 00079767), pp. 1-2, 4, 35. *Exceeds 30 pages*.

**J.** Japan Assistance Team for Small Arms Management in Cambodia, "Weapons Collection Record 2005-2007" (JSAC, 2007).

**K.** Christine Wille, "How Many Weapons Are There in Cambodia?", Small Arms Survey Working Paper (Geneva: Small Arms Survey, 2005), pp. 1-11, 20-29, 30-44. *Exceeds 30 pages*.

**L.** "Summary of the Speech of Mr. Thor Saron, Cambodian Judge", in *National Workshop Report on Awareness Raising in Arms Law, July 16-18, 2006*, pages 15-16 (Working Group on Weapons Reduction, 2006), pp. 1-6, 8, 15-17. *Exceeds 30 pages*.

| | | |
|---|---|---|
| **Nature of documents:** | Public Filing: ☒ | **Confidential:** ☐ |
| **Other** (give explanation below) | | |
| Ex Parte: ☐ | Urgent: ☐ | Late filing: ☐ |
| | | |

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
THE PRE - TRIAL CHAMBER OF THE ECCC
លេខ No.: C01
ថ្ងៃទី Date: 03-10-2007
ម៉ោងចូល Time: 11H00 AM

00154559

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

| | |
|---|---|
| សំណុំរឿងព្រហ្មទណ្ឌលេខ៖ | ០០២/១៩-០៩-២០០៦ |
| លេខស៊ើបសួរ៖ | ០០១/១៨-០៧-២០០៧ |
| ឈ្មោះសំណុំរឿង៖ | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ |
| បញ្ជូនទៅ៖ | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទនៃការបញ្ជូន៖ | ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៧ |
| ភាគីបញ្ជូន៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម៖ | ភាសាអង់គ្លេស |
| ប្រភេទឯកសារ៖ | **ជាសាធារណៈ** |

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា តបទៅ បណ្តឹងឧទ្ធរណ៍របស់មេធាវី ដែលប្រឆាំងនឹង ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន របស់សហចៅក្រមស៊ើបអង្កេត លើឈ្មោះ កាំង ហ្កេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧**

---

**<u>បញ្ជូនដោយ៖</u>**
**ការិយាល័យហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉ែត ចរិយា
លោក William SMITH
លោក ពេជ្រ សម្បត្តិ
លោក Alex BATES

**<u>ចែកចាយជូន៖</u>**
**ចៅក្រមអង្គបុរេជំនុំជម្រះ៖**
ឯ.ឧ. ប្រាក់ គឹមសាន
ឯ.ឧ. ន័យ ថុល
លោក ហួត វុទ្ធី
លោកស្រី Katinka LAHUIS
លោក Rowan DOWNING

**សហចៅក្រមស៊ើបអង្កេត៖**
លោក យូ ប៊ុនឡេង
លោក Marcel LEMONDE
**មេធាវីការពារក្តី៖**
លោក ការ សាវុត្ថ
លោក Francois ROUX

# សេចក្តីផ្តើម
# ប្រវត្តិនៃនីតិវិធី

១. កាំង ហ្កេចអ៊ាវ ("ជនត្រូវចោទ") ត្រូវចាប់ និងឃុំខ្លួនមុនការកាត់ទោស ជាដំបូងដោយតុលាការយោធានៃទីក្រុងភ្នំពេញ ("តុលាការយោធា") ក្នុងឆ្នាំ១៩៩៩ ។ បើតាមក្នុងកំណត់ត្រាដែលអាចរក បានបង្ហាញឲ្យឃើញថា ការស៊ើបសួរមួយត្រូវបានបើកធ្វើឡើងប្រឆាំងនឹងរូបគាត់ ហើយគាត់ត្រូវឋិតនៅក្នុងការឃុំខ្លួនជាបន្តរហូតជាប់មិនដាច់ដោយតុលាការយោធា ចាប់តាំងពីឆ្នាំ ១៩៩៩ ។ នីតិវិធីបែបនេះ តាមការយល់ដឹងរបស់សហព្រះរាជអាជ្ញា គឺកំពុងនៅបន្តចាត់ការនៅឡើយ ។

២. សហព្រះរាជអាជ្ញា បានបញ្ជូន ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ប្រឆាំងនឹងជនសង្ស័យដែលមានឈ្មោះចំនួនប្រាំរូប កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ដោយបានស្នើសុំឲ្យបើកធ្វើការស៊ើបសួរមួយ ហើយសុំឲ្យធ្វើការចាប់ និងឃុំខ្លួនជាបណ្តោះអាសន្នលើជនសង្ស័យទាំងប្រាំរូប ។

៣. ជនត្រូវចោទ ត្រូវបានចាប់ខ្លួនតាមដីកាមួយរបស់ សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃ ទី៣០ ខែកក្កដា ឆ្នាំ២០០៧ ។ ថ្ងៃបន្ទាប់មក គាត់ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុង ឆ្នាំ១៩៧៥ រហូតដល់ ឆ្នាំ១៩៧៩ ពេលដែលគាត់ត្រូវបានចោទថាបានដឹកនាំទិសដៅការងារនៅមណ្ឌលសន្តិសុខ ស-២១ នៅទីក្រុងភ្នំពេញ ("ស-២១") ។ បន្ទាប់ពីមានកិច្ចពិភាក្សាដេញដោលមួយរួចមក សហចៅក្រមស៊ើបអង្កេត បានសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ចំនួនមួយឆ្នាំ ដូចដែលបានបញ្ជាក់នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ។

៤. ជនត្រូវចោទ បានប្តឹងឧទ្ធរណ៍លើដីកាសម្រេចនេះ តាមរយៈសារណាជាលាយលក្ខអក្សរ ចុះថ្ងៃទី២៣ ខែសីហា និង ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៧ ("បណ្តឹងឧទ្ធរណ៍របស់មេធាវី

ការពារក្តី") ។ សហព្រះរាជអាជ្ញា បានទទួលបណ្តឹងឧទ្ធរណ៍នេះ ជាភាសាអង់គ្លេស នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ ហើយតាមដីការបស់អង្គបុរេជំនុំជម្រះ ត្រូវមានចំនួន ១៥ថ្ងៃ ចាប់តាំងពីថ្ងៃនេះ (ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៧) ត្រូវដាក់ពាក្យឆ្លើយតបមួយ ។

## បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី

៥. មេធាវីការពារក្តី បានស្នើសុំឱ្យមានសវនាការផ្ទាល់មាត់មួយត្រូវធ្វើឡើងជាសាធារណៈ អំពីបណ្តឹងឧទ្ធរណ៍នេះ ។

៦. បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី មានចំណុចសំខាន់ៗ ចំនួនពីរ៖

(i) ទឡ្ហីករណ៍សំរាប់ចេញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន មិនត្រូវទៅតាមវិធាន ៦៣.៣ នៃវិធានផ្ទៃក្នុងសំរាប់ អ.វ.ត.ក ("វិធានផ្ទៃក្នុង") ទេ ។

(ii) ជនត្រូវចោទ ត្រូវតែបានដោះលែងជាបន្ទាន់ ពីព្រោះថា រយៈពេលដ៏លើសលប់ដែលគាត់បានឋិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ គឺជាការបំពារបំពានលើច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិ សំរាប់ការការពារសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការកាត់ក្តីក្នុងរយៈពេលដ៏សមស្របមួយ ។

៧. បន្ថែមលើនេះ ជនត្រូវចោទ បានធ្វើសំណើបន្ថែមទៀត ចំនួនពីរ៖

(i) នៅក្នុងព្រឹត្តិការណ៍ដែលគេកំណត់ថា បានត្រូវទៅតាម វិធាន៦៣.៣ ហើយនោះ សូមស្នើឱ្យ សម្រេចដាក់គាត់ឱ្យឋិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

(ii) សូមស្នើឱ្យ អង្គបុរេជំនុំជម្រះ ធ្វើការប្រកាសនៅក្រោយពេលបញ្ចប់សវនាការ ថា ជនត្រូវចោទ ត្រូវបានទទួលសំណងទូទាត់ហិរញ្ញវត្ថុ បើសិនជាត្រូវបានសំរេចឱ្យរួចខ្លួន ហើយថាត្រូវមានការកាត់បន្ថយក្នុងការដាក់ទោសបើសិនជាត្រូវបានសំរេចឱ្យជាប់ទោស ដែលជាដំណោះស្រាយបន្ថែមមួយ ចំពោះការបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការកាត់ក្តីក្នុងរយៈពេលដ៏សមស្របមួយ ។

00154562



## ចម្លើយតបរបស់សហព្រះរាជអាជ្ញា

៨. សហព្រះរាជអាជ្ញា យល់ព្រមថា សវនាការផ្ទាល់មាត់ស្តីពីបណ្តឹងឧទ្ធរណ៍នេះ ត្រូវធ្វើឡើងជាសាធារណៈ ហើយសូមស្នើឲ្យ អង្គបុរេជំនុំជម្រះ ចេញដីកាសម្រេចយ៉ាងដូច្នោះ ។

៩. សហព្រះរាជអាជ្ញា សូមស្នើឲ្យធ្វើការបដិសេធទាំងស្រុង នូវបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ហើយដំកល់ទុកដីការបស់សហចៅក្រមស៊ើបអង្កេត ដែលសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទចំនួនមួយឆ្នាំនោះ ថាបានបញ្ជាក់ដាច់ស្រេចជាស្ថាពរហើយ ពីព្រោះ៖

(i) សហចៅក្រមស៊ើបអង្កេត គឺត្រឹមត្រូវ ក្នុងការរកឃើញនូវហេតុផល សំរាប់ចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ដែលត្រូវទៅតាម តាមវិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង **(សំណើ ក)** ។

(ii) សហចៅក្រមស៊ើបអង្កេត មិនមានខុសអ្វី ក្នុងការខកខានមិនបានបង្ហាញភ្លាមៗដល់ជនត្រូវចោទ អំពីសិទ្ធិរបស់គាត់ ក្នុងការទទួលបាននូវការកាត់ក្តីក្នុងរយៈពេលដ៏សមស្របមួយនោះទេ ពីព្រោះ **(សំណើ ខ)** ៖

(ក) ការបំពានបែបនោះ គឺមិនត្រូវបានភ្ជាប់(កាតព្វកិច្ច) ទៅនឹង អ.វ.ត.ក នោះទេ **(ផ្នែកទី I)** ។ និង

(ខ) ការបំពានបែបនោះ គឺមិនមែនជាស្ថានទម្ងន់ តាមបែបដែលតម្រូវឲ្យ អ.វ.ត.ក ទទួលនោះទេ ។ អ.វ.ត.ក ជាតុលាការមួយតម្រូវឲ្យទទួលតែករណីណាដែលមានការបំពានយ៉ាងធ្ងន់ធ្ងរ លើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដើម្បីផ្តល់ដល់ជនត្រូវចោទ នូវដំណោះស្រាយមួយ ក្នុងដំណាក់ការនៃការស៊ើបសួរ តែប៉ុណ្ណោះ **(ផ្នែកទី II)** ។

១០. បន្ថែមលើនេះ សហព្រះរាជអាជ្ញា ស្នើសុំឲ្យអង្គបុរេជំនុំជម្រះធ្វើការវិនិច្ឆ័យសេចក្តីមួយ អំពីការបកស្រាយដ៏ត្រឹមត្រូវតាមវិធាននានាដែលពាក់ព័ន្ធនឹង ការដាក់បញ្ជូនឯកសារ ទៅចំពោះមុខ អ.វ.ត.ក ។ មានរឿងលេចឡើងថា ឯកសារបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ មិនមានភាពពេញលក្ខណៈទេ ដោយគ្មានទាំងទឡ្ហីករណ៍ គ្មានទាំង

សេចក្តីសំអាង[1] ។ វាក៏មានរឿងលេចឡើងផងដែរថា ឯកសារបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៧ មិនត្រឹមត្រូវតាម វិធាន៧៥[2] នៃវិធានផ្ទៃក្នុងទេ ដែលថាឯកសារនោះ ត្រូវបានបញ្ជូនដោយហួសពេលចំនួនប្រាំថ្ងៃ ។ មេធាវីការពារក្តី មិនបានស្នើសុំតាម វិធាន៣៩.៤ នៃវិធានផ្ទៃក្នុងទេ[3] ទាំងការពន្យារពេលសំរាប់ដាក់បញ្ជូនឯកសាររបស់ពួកគាត់ នៅថ្ងៃ ទី០៥ ខែកញ្ញា ឆ្នាំ២០០៧ ទាំងដីកាទទួលស្គាល់សុពលភាពនៃឯកសារនេះ ដែលបានដាក់បញ្ជូនក្រោយពេលដែលបានកំរិតក្តី ។ នៅពេលដែលមិនមានភាពច្បាស់លាស់ទាំងស្រុង អំពីថាតើ រយៈពេលកំណត់ចំនួន៣០ថ្ងៃសំរាប់ដាក់បញ្ជូនឯកសារនោះ ពាក់ព័ន្ធនឹងខ្លឹមសារនៃបណ្តឹងឧទ្ធរណ៍ដែរ ឬមួយក៏ គ្រាន់តែសំរាប់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ អង្គបុរេជំនុំជម្រះ ត្រូវបានអញ្ជើញសុំឲ្យធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីបញ្ហានេះ សំរាប់ភាពជាក់លាក់ក្នុងការបកស្រាយវិធាននៅពេលអនាគត ។

## សវនាការសាធារណៈ

១១. សហព្រះរាជអាជ្ញា ចូលរួមជាមួយនឹង មេធាវីការពារក្តី ក្នុងការដាក់ស្នើថាដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ អង្គបុរេជំនុំជម្រះ ត្រូវប្រកាសថាសវនាការផ្ទាល់មាត់ស្តីពីបណ្តឹងឧទ្ធរណ៍នេះ នឹងត្រូវធ្វើឡើងជាសាធារណៈ ដោយយោងតាមវិធាន ៧៧.៦ នៃវិធានផ្ទៃក្នុង[4] ។

---

[1] សេចក្តីព្រាងអំពីសេចក្តីណែនាំសំរាប់អនុវត្ត ស្តីពីការដាក់សេចក្តីសន្និដ្ឋាននៅចំពោះមុខ អ.វ.ត.ក មិនទាន់ចូលជាធរមាននៅឡើយទេ នៅពេលសរសេរចម្លើយតបនេះ ។

[2] វិធាន ៧៥ ចែងថា "លើកលែងតែមានចែងផ្សេងនៅក្នុងវិធានផ្ទៃក្នុងនេះ គ្រប់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ត្រូវតែធ្វើឡើងក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងពីសេចក្តីសម្រេច ឬ ដីកា ។ មេធាវីរបស់ជនត្រូវចោទ... អាចដាក់បណ្តឹងឧទ្ធរណ៍ក្នុងនាមជនត្រូវចោទ... បាន" ។

[3] វិធាន ៣៩.៤ ចែងថា "*តាមរយៈពាក្យបណ្តឹងរបស់ភាគីពាក់ព័ន្ធ* សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាច៖ (ក) ពន្យារពេលវេលាកំណត់ដែលខ្លួនបានសម្រេច, (ខ) ទទួលស្គាល់ថាមានសុពលភាពចំពោះកិច្ចទាំងឡាយណា ដែលបានអនុវត្តក្រោយពេលវេលាកំណត់ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ ត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល" ។ *(សង្កត់ន័យបន្ថែមដោយអក្សរទ្រេត)* ។

[4] វិធាន ៧៧.៦ ចែងថា "តាមសំណើរបស់ចៅក្រមណាម្នាក់ ឬ របស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចថា នីតិវិធីទាំងស្រុង ឬមួយផ្នែកនៃសវនាការត្រូវធ្វើឡើងជាសាធារណៈ ... បើអង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ វិធានការការពាររបស់តុលាការ" ។

១២. អ.វ.ត.ក គឺជាតុលាការព្រហ្មទណ្ឌដំបូង ដែលត្រូវធ្វើការវិនិច្ឆ័យសេចក្តីលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយចោទប្រកាន់លើអ្នកដឹកនាំជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់បំផុតដទៃទៀត ។ ដូច្នេះ ការចាប់ផ្តើមនីតិវិធីតុលាការនៅចំពោះមុខ អ.វ.ត.ក គឺជាឱកាសប្រវត្តិសាស្ត្រមួយសំរាប់ពលរដ្ឋកម្ពុជា ក៏ដូចជាពលរដ្ឋមិនមែនកម្ពុជាដែរ ។

១៣. ដូចដែលត្រូវបានអនុញ្ញាតតាមច្បាប់ដែលអាចយកមកអនុវត្តបាន ព្រមទាំងដោយត្រូវគោរពតាមកិច្ចការពារសាក្សី និងជនរងគ្រោះ សហព្រះរាជអាជ្ញា សូមស្នើថាសវនាការនៅចំពោះមុខ អ.វ.ត.ក ត្រូវធ្វើឡើងជាសាធារណៈ ដើម្បីឲ្យគេមើលឃើញថា មានយុត្តិធម៌ ។ តាមគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ សវនាការនៅក្នុងតុលាការ រួមទាំងសវនាការអំពីការឃុំខ្លួនផង ត្រូវធ្វើឡើងជាសាធារណៈ[5] ។ ការប្រព្រឹត្តិទៅដែលប្រកបដោយយុត្តិធម៌ និងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ គឺជាបញ្ហាមួយដែលសាធារណៈជនចាប់អារម្មណ៍ និងលើសពីនេះទៀត គឺនៅពេលដែលសហគមន៍អន្តរជាតិទាំងមូល មានការចាប់អារម្មណ៍អំពីសាច់រឿងវិវាទនោះ ។

## សំណើ ក

## ទឡ្ហីករណ៍សំរាប់ការឃុំខ្លួនបណ្តោះអាសន្ន តាមវិធាន ៦៣.៣

១៤. សហព្រះរាជអាជ្ញា សូមស្នើថា មិនមានជាកំហុសអ្វីទេ ក្នុងការយល់ឃើញថាមានទឡ្ហីករណ៍ផ្សេងៗសំរាប់ធ្វើការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។ ដោយអនុលោមតាមវិធាន ៦៣.៣ មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទបានប្រព្រឹត្តបទល្មើសផ្សេងៗដូចដែលបានចោទនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ។

[5] មាត្រា ១៤.១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ, GA Res 2200A (XXI), U.N.Doc.A/6316 (1966), 999 UNTS 171, ដែលបានចូលជាធរមាននៅថ្ងៃទី២៣ មិនា ១៩៧៦, ចែងថា៖ “...បុគ្គលគ្រប់រូបមានសិទ្ធិស្នើសុំឲ្យមានការកាត់សេចក្តីមួយដ៏មានយុត្តិធម៌ និងជាសាធារណៈ ...” ។

មានមូលដ្ឋានភស្តុតាងដ៏រឹងមាំផងដែរ ក្នុងការរកឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការមួយដ៏ចាំបាច់តាម វិធាន៦៣.៣ ដើម្បី៖ ១) រារាំងកុំអោយមានការគាបសង្កត់ទៅលើសាក្សី ឬ រារាំងកុំអោយមានការត្រូវរូវគ្នាជាមួយនឹងអ្នកសមគំនិតផ្សេងៗ, ២) ធានាអំពីវត្តមានរបស់ជនត្រូវចោទ, ៣) ការពារសន្តិសុខអោយជនត្រូវចោទ, ហើយលើស ពីនេះ, ៤) រក្សាសណ្តាប់ធ្នាប់សាធារណៈ ។

១៥. សហព្រះរាជអាជ្ញា សូមស្នើបន្ថែមទៀតថា ការរកឃើញរបស់ សហចៅក្រមស៊ើបអង្កេត មិនមានកំហុសឆ្គងអ្វីទេដែលថា មិនមានលក្ខខណ្ឌអ្វីក្នុងការធានាឲ្យបានគ្រប់គ្រាន់អំពីវត្តមានរបស់ជនត្រូវចោទ ដែលត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាម វិធាន៦៥ ព្រមទាំងធានាអំពីការការពារជនដទៃទៀត នោះទេ ។

**អង្គច្បាប់**

**ប្រភព និងបទដ្ឋានច្បាប់នៅក្នុង អ.វ.ត.ក**

១៦. ក្នុងការអនុវត្តន៍ច្បាប់នីតិវិធីនៅក្នុង អ.វ.ត.ក. ដូចជា ច្បាប់ពាក់ព័ន្ធនឹងការឃុំខ្លួនមុនការជំនុំជម្រះ អង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែប្រើច្បាប់ជាតិ និងច្បាប់អន្តរជាតិធ្វើជាប្រភពច្បាប់របស់ពួកគេ ទៅតាមស្មារតីនៃកិច្ចព្រមព្រៀង ក្នុងការបង្កើតឱ្យមានអង្គជំនុំជម្រះនេះ ។ បទដ្ឋានដែលច្បាប់នេះត្រូវប្រតិបត្តិតាមនោះ ត្រូវតែបានទទួលស្គាល់ជាអន្តរជាតិទៅតាមស្មារតីនៃមាត្រា ១២(២) នៃកិច្ចព្រមព្រៀង ដែលចែងថា៖ "អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របតាមច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជា គឺជាភាគីហត្ថលេខីដែរ" ។

១៧. ដើម្បីឲ្យសម្រេចបាននូវបទដ្ឋានយុត្តិធម៌អន្តរជាតិនេះ មាត្រា ១២(១) នៃកិច្ចព្រមព្រៀង បានចែងយ៉ាងច្បាស់ថា នីតិវិធីរបស់អង្គជំនុំជម្រះនេះត្រូវសមស្របជាមួយច្បាប់នីតិវិធីកម្ពុជា និងវិធាននីតិវិធីអន្តរជាតិ ។ កិច្ចព្រមព្រៀងនេះបានទទួលស្គាល់ភាពដែលមានតែមួយគត់នៃ

អាណាត្តិរបស់ អ.វ.ត.ក ហើយជំរុញឱ្យអង្គជំនុំជម្រះនេះអនុវត្តវិធាននីតិវិធីដែលបានបង្កើតឡើងក្នុងកំរិតអន្តរជាតិ នៅពេលណាដែល៖

(i) ច្បាប់កម្ពុជា មិនពាក់ព័ន្ធនឹងបញ្ហាជាក់លាក់ណាមួយ, ឬ

(ii) មានភាពមិនច្បាស់លាស់ ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តន៍បទប្បញ្ញត្តិណាមួយដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា, ឬក៏

(iii) មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នា រវាងបទប្បញ្ញត្តិបែបនេះទៅនឹង បទដ្ឋានអន្តរជាតិ ។

១៨. អង្គជំនុំជម្រះវិសាមញ្ញ ក៏បានទទួលស្គាល់ភាពដែលមានតែមួយគត់នៃសាច់រឿងវិវាទរបស់អង្គជំនុំជម្រះនេះផងដែរ តាមរយៈកិច្ចប្រជុំពេញអង្គរបស់ចៅក្រម ដែលបានប្រមូលនីតិវិធីកម្ពុជានានាដែលអាចអនុវត្តបាន យកមកប្រើក្នុង អ.វ.ត.ក ។ ចៅក្រមទាំងនោះបានយល់ព្រមលើបណ្តុំវិធានផ្ទៃក្នុង ដែលមានបទបញ្ញាជាក់លាក់មួយចំនួន សំរាប់គ្រប់គ្រងលើដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះ ។ ទាំងវិធានផ្ទៃក្នុង ទាំងច្បាប់ អ.វ.ត.ក បានផ្តល់ នូវប្រសិទ្ធិភាពជាក់លាក់ដល់កិច្ចព្រមព្រៀងរវាង អង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ។

១៩. ហេតុដូច្នេះហើយ សូមស្នើឱ្យ អង្គបុរេជំនុំជម្រះ ត្រូវតែយោងទៅលើវិធាននីតិវិធី និងយុត្តិសាស្ត្រអន្តរជាតិថែមទៀត ដើម្បីជាការបង្គ្រប់ដល់ការយោងតែទៅលើវិធានផ្ទៃក្នុង អំពីបញ្ហាផ្សេងៗដូចជាការឃុំខ្លួនបណ្តោះអាសន្នជាដើម ក្នុងគោលបំណងដើម្បីឱ្យត្រូវតាមបទដ្ឋានអន្តរជាតិដូចដែលបានតម្រូវដោយ មាត្រា១២(២) នៃកិច្ចព្រមព្រៀង ។ លើសពីនេះទៀត សូមស្នើដាក់ជូនថា វិធាននីតិវិធីអន្តរជាតិដែលកំពុងត្រូវបានបង្កើតឡើង តាមរយៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និង តុលាការអន្តរជាតូបនីយកម្ម ដែលមានការជាប់ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនេះ គឺជាបទដ្ឋានអន្តរជាតិ ដែលមានការជាប់ទាក់ទិនច្រើនបំផុតដែល អ.វ.ត.ក ត្រូវយកលំនាំតាម ។

២០. មេធាវីការពារក្តី បានដកស្រង់(ពីសំណុំរឿង) យ៉ាងច្រើនរបស់តុលាការ និងគណៈកម្មាធិការថ្នាក់តំបន់ និងថ្នាក់ខ្ពស់ជាងជាតិ ដូចជា៖ តុលាការអឺរ៉ុបស្តីពីកិច្ចការសិទ្ធិមនុស្ស ("ECHR") (ដែលជាតុលាការមួយក្នុងតំបន់ដែលទទួលសំណុំរឿងពីតុលាការថ្នាក់ជាតិ) និងគណៈកម្មាធិការសិទ្ធិមនុស្ស ("HRC") (ដែលតាមពិតទៅ វាមិនមែនជាតុលាការទេ ក៏ប៉ុន្តែជាគណៈកម្មាធិការមួយ ដែលបង្កើតឡើងដើម្បីធ្វើការកំណត់អំពីការប្រព្រឹត្តិ ឲ្យត្រូវតាមកតិកាសញ្ញាអន្តរជាតិស្តីអំពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") ។ សហព្រះរាជអាជ្ញាសូមស្នើថា បើទោះបីជាមានសំណុំរឿងនៅក្នុងតុលាការ ECHR និងនៅក្នុងគណៈកម្មាធិការ HRC ដែលអាចនឹងផ្តល់នូវការណែនាំស្តីពីគោលការណ៍ទូទៅ[6] ក៏ដោយក៏ សាច់រឿងវិវាទនៃសំណុំរឿងទាំងនោះ គឺខុសគ្នាទាំងស្រុងពីអ្វីដែលកំពុងមាននៅចំពោះមុខអ.វ.ត.ក ឬនៅចំពោះមុខតុលាការដទៃទៀត ដែលកាត់សេចក្តីពីការរំលោភធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និងប្រទេសរវ៉ាន់ដា ("ICTY" និង "ICTR") និង តុលាការពិសេសសំរាប់ប្រទេសសេរ៉ាឡេអូន ("SCSL") ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ ត្រូវបានស្នើសុំឲ្យមានការប្រុងប្រយ័ត្នយ៉ាងខ្លាំងក្នុងការពិនិត្យលើសំណុំរឿងផ្សេងៗពីតុលាការ និងគណៈកម្មាធិការ ថ្នាក់តំបន់និងថ្នាក់ខ្ពស់ជាងជាតិ បែបទាំងនោះ។

## ទឡ្ហីករណ៍ក្នុងវិធាន ៦៣.៣

២១. វិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង ចែងថា សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទបានតែក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

[6] ដូចដែលបានសំរេចក្នុងសំណុំរឿង *ព្រះរាជអាជ្ញា ទល់នឹង Jean Bosco Barayagwiza*, សំណុំរឿងលេខ ICTR-97-19-AR72, សាលាឧទ្ធរណ៍នៃតុលាការ ICTR, ចុះថ្ងៃទី០៣ វិច្ឆិកា ១៩៩៩, កថាខណ្ឌទី ៤០, ប្រភពបែបដូច្នេះ គឺជា "អំណាចនៃការបញ្ចុះបញ្ចូលដែលអាចជួយដល់ការអនុវត្តន៍ និងបកស្រាយច្បាប់ដែលអាចអនុវត្តបានក្នុងតុលាការនេះ " ។

"ក-មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម ។

ខ-សហចៅក្រមស៊ើបអង្កេត យល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី៖

(១) រារាំងកុំអោយជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំអោយមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និង អ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុះជម្រះវិសាមញ្ញ ។

(២) ថែរក្សាភស្តុតាង ឬ ការពារមិនអោយបំផ្លាញភស្តុតាង

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី

(៤) ការពារសន្តិសុខអោយជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ ។"

២២. មូលហេតុប្រាំបែបក្នុងវិធាន ៦៣.៣.ខ *គឺដាច់ៗគ្នា* ។ មិនមានលក្ខខណ្ឌតម្រូវអ្វីសំរាប់ឲ្យសហចៅក្រមស៊ើបអង្កេតរកឲ្យឃើញថា ត្រូវតែមានគ្រប់មូលដ្ឋានទីមួយៗសិន មុននឹងពួកគាត់សំរេចថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការមួយដ៏ចាំបាច់ ទេ។ ផ្ទុយទៅវិញបើសហចៅក្រមស៊ើបអង្កេតអាចពិចារណាឃើញថាមានមូលហេតុ *តែមួយ* ក្នុងចំណោមមូលហេតុទាំងប្រាំនោះ ផ្នែកតែមួយនេះគឺគ្រប់គ្រាន់ហើយសំរាប់ការឃុំខ្លួនបណ្តោះអាសន្ន ។ វិធីនេះត្រូវបាន គេយកទៅអនុវត្ត នៅចំពោះមុខតុលាការផ្សេងៗទៀត ដែលកាត់សេចក្តីលើសំណុំរឿងឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ[7] ។

[7] *ព្រះរាជអាជ្ញា ទល់នឹង Sainovic និង Odjanic,* សេចក្តីសំរេចដែលបដិសេធសំណើប្តឹងឧទ្ធរណ៍របស់ Odjanic សំណុំរឿងលេខ IT-99-37-AR65.2 សាលាឧទ្ធរណ៍របស់តុលាការ ICTY ចុះថ្ងៃទី២៧ មិថុនា ២០០៣, កថាខណ្ឌទី ៤ ។

00154569



២៣. បន្ថែមលើនេះ បទដ្ឋានដែលសហចៅក្រមស៊ើបអង្កេត ត្រូវពឹងផ្អែកក្នុងការពិចារណា អំពីទឡ្ហីករណ៍ប្រាំបែបនោះគឺថា ពួកគាត់ត្រូវមានការ "យល់ឃើញ" ថាមូលដ្ឋាននោះត្រូវបានរកឃើញ ។ មិនមានលក្ខខណ្ឌណាមួយតម្រូវឱ្យបង្ហាញភស្តុតាង អំពីអត្ថិភាពនៃទឡ្ហីករណ៍ទាំងនោះ ឱ្យហួសពីវិមតិសង្ស័យ ឬក៏ទាំងមិនត្រូវបង្ហាញពី តុល្យភាពនៃភវនីយភាព (លទ្ធភាពដែលអាចបញ្ជាក់ថាពិត) នោះទេ ។

២៤. សហចៅក្រមស៊ើបអង្កេតរបស់ អ.វ.ត.ក មានឆន្ទានុសិទ្ធិមួយក្នុងការសំរេច អំពីរបៀបដែលពួកគាត់បានឈានទៅដល់ សេចក្តីសន្និដ្ឋានមួយដែលថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការមួយដ៏ចាំបាច់ ។ ឆន្ទានុសិទ្ធិ របស់តុលាការបែបនេះ ជាទូទៅត្រូវបានគេអនុវត្តដោយយកចិត្តទុកដាក់លើគ្រប់លក្ខណៈទាំងអស់នៃសំណុំរឿង ដូចជា ស្ថានទម្ងន់នៃបទចោទប្រកាន់ ប្រភេទភស្តុតាង ទង្វើនិងការប្រព្រឹត្តិរបស់ជនសង្ស័យទាំងបច្ចុប្បន្នកាលនិងអតីតកាល ផលប្រយោជន៍របស់ជនរងគ្រោះនិងសាក្សី ព្រមទាំង ផលប្រយោជន៍នៃយុត្តិធម៌ទាំងមូល ។ សេចក្តីសំរេចថ្មីៗបំផុតរបស់តុលាការ ICTY បានអះអាងថាបញ្ហានេះ ក៏ត្រូវបានគេទទួលយកទៅអនុវត្តផងដែរ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[8] ។

## បទដ្ឋានក្នុងការពិនិត្យសារឡើងវិញ

[8] *ព្រះរាជអាជ្ញា ទល់នឹង Ljube Boskoski និង Johan Tarculovski,* សេចក្តីសំរេចពី បណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បន្ទំ របស់ Johan Tarculovski ស្តីពីការដោះលែងជាបណ្តោះអាសន្ន, សំណុំរឿងលេខ IT-04-82-AR65.4 សាលាឧទ្ធរណ៍របស់តុលាការ ICTY ចុះថ្ងៃទី២៧ កក្កដា ២០០៧ កថាខណ្ឌទី ៤ ។ សូមអានផងដែរ *ព្រះរាជអាជ្ញា ទល់នឹង Popovic និង គូកន,* សេចក្តីសំរេចពី បណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បន្ទំ របស់សាលាដំបូង សំរេចបដិសេធសេចក្តីស្នើរបស់ Drago Nicolic សំរាប់សុំឱ្យមានការដោះលែងជាបណ្តោះអាសន្ន, សំណុំរឿងលេខ IT-05-88-AR65.1 សាលាឧទ្ធរណ៍របស់តុលាការ ICTY ចុះថ្ងៃទី២៤ មករា ២០០៦ ទំព័រទី ៣ ហើយនឹង *ព្រះរាជអាជ្ញា ទល់នឹង Milosovic,* ហេតុផលសំរាប់សេចក្តីសំរេចពី បណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បន្ទំ ចេញពីការបដិសេធន៍លើ ដីកាដាក់បញ្ចូល(សំណុំរឿង), សំណុំរឿងលេខ IT-99-37-AR73, សាលាឧទ្ធរណ៍របស់តុលាការ ICTY ចុះថ្ងៃទី១៨ មេសា ២០០២, កថាខណ្ឌទី ៣-៦ ។

២៥. ទោះបីជាមិនមានការណែនាំ ទាំងនៅក្នុងវិធានផ្ទៃក្នុង ទាំងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា អំពីមូលដ្ឋានក្នុងការអនុវត្តន៍ឆន្ទានុសិទ្ធិរបស់តុលាការ ពាក់ព័ន្ធនឹងបញ្ហាឃុំខ្លួនបណ្ដោះអាសន្ន ដែលអាចនឹងត្រូវបានតទល់នៅពេលឧទ្ធរណ៍ ក៏ដោយក៏ តុលាការអន្តរជាតិនានាបានអនុវត្តនូវ បទដ្ឋានក្នុងការពិនិត្យសារឡើងវិញមួយដ៏ហ្មត់ចត់ ។ គឺមានតែនៅពេលដែលគេអាចបង្ហាញបានថា "កំហុសដែលអាចវិនិច្ឆ័យថាខុសឬត្រូវបាន" (Discernable error) ដែលត្រូវធ្វើឡើងដោយតុលាការជាន់ទាប នៅក្នុងការអនុវត្តន៍ឆន្ទានុសិទ្ធិរបស់ខ្លួនប៉ុណ្ណោះទេ ដែលបណ្ដឹងឧទ្ធរណ៍មួយត្រូវបានទទួលជោគជ័យនោះ ។ វាមិនមែនជាកិច្ចការរបស់សាលាឧទ្ធរណ៍ ដែលត្រូវប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ធ្វើការសម្រេចជំនួសឆន្ទានុសិទ្ធិរបស់តុលាការជាន់ទាបមួយ នោះទេ ។ ដូចដែលសាលាឧទ្ធរណ៍នៃ តុលាការ ICTY បានចែងនៅក្នុងសំណុំរឿងរវាង *ព្រះរាជអាជ្ញា ទល់នឹង Ljube Boskoski និង Johan Tarculovski*[9]៖ *"សំនួរពាក់ព័ន្ធ គឺមិនមែនថាតើ សាលាឧទ្ធរណ៍យល់ព្រម ទៅនឹងសេចក្ដីសំរេចដែលប្រកបទៅដោយឆន្ទានុសិទ្ធិនោះឡើយ ក៏ប៉ុន្តែ "ថាតើសាលាជំនុំជម្រះដំបូង បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានយ៉ាងត្រឹមត្រូវ មុននឹងឈានទៅដល់សេចក្ដីសំរេចនោះ ឬ យ៉ាងដូចម្ដេច""* ។

២៦. សាលាឧទ្ធរណ៍នៃតុលាការ ICTY បានបន្តកាត់សេចក្ដីតទៅទៀត ដោយឲ្យនិយមន័យអំពី "កំហុសដែលអាចវិនិច្ឆ័យថាខុសឬត្រូវបាន"ថា៖ *"(១) មានមូលដ្ឋាននៅលើការបកស្រាយមួយដែលមិនត្រឹមត្រូវអំពីច្បាប់សំរាប់គ្រប់គ្រង, (២) មានមូលដ្ឋាននៅលើសេចក្ដីសន្និដ្ឋានមិនត្រឹមត្រូវយ៉ាងជាក់ស្ដែងអំពីអង្គហេតុ, ឬ(៣) មិនមានយុត្តិធម៌និងមិនសមហេតុផលយ៉ាងហួសហេតុពេកបណ្ដាលឲ្យទៅជាមានការបំពានមួយលើឆន្ទានុសិទ្ធិរបស់សាលាជំនុំជម្រះក្ដី"*[10] ។

---

[9] *Ljube Boskoski និង Johan Tarculovski*, សេចក្ដីសំរេចពី បណ្ដឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បន្ថែ របស់ Johan Tarculovski ស្ដីពីការដោះលែងជាបណ្ដោះអាសន្ន, សំណុំរឿងលេខ IT-04-82-AR65.4 សាលាឧទ្ធរណ៍របស់តុលាការ ICTY, ចុះថ្ងៃទី២៧ កក្កដា ២០០៧ កថាខណ្ឌទី ៤ ដែលបានដកស្រង់ *ព្រះរាជអាជ្ញា ទល់នឹង Prlic និង គូកន* , សេចក្ដីសំរេចជាសម្ងាត់អំពីបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា នៃសាលាដំបូង៖ "Décision relative à la demande de mise en liberté provisoire de l'accusé Pusié", សំណុំរឿងលេខ IT-04-74-AR65.4 សាលាឧទ្ធរណ៍របស់តុលាការ ICTY, ចុះថ្ងៃទី២០ កក្កដា ២០០៧ កថាខណ្ឌទី ៦ ។

[10] *Ljube Boskoski និង Johan Tarculovski* , សេចក្ដីសំរេចពី បណ្ដឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បន្ថែ របស់ Johan Tarculovski ស្ដីពីការដោះលែងជាបណ្ដោះអាសន្ន, សំណុំរឿងលេខ IT-04-82-AR65.4 សាលាឧទ្ធរណ៍របស់តុលាការ ICTY, ចុះថ្ងៃទី២៧ កក្កដា ២០០៧ កថាខណ្ឌទី ៤ ។

២៧. សហព្រះរាជអាជ្ញា សូមស្នើថា បទដ្ឋានក្នុងការពិនិត្យសារឡើងវិញនេះត្រូវតែបានជាការណែនាំដល់អង្គបុរេជំនុះជម្រះ ក្នុងការពិនិត្យសារឡើងវិញរបស់ខ្លួន អំពីឆន្ទានុសិទ្ធិដែលសហចៅក្រមស៊ើបអង្កេត បានអនុវត្តកន្លងមក ។

## បន្ទុកនៃភស្តុតាង

២៨. បន្ទុកក្នុងការបង្ហាញថា សហចៅក្រមស៊ើបអង្កេត បានប្រើប្រាស់នូវឆន្ទានុសិទ្ធិរបស់ខ្លួនដោយមានកំហុសក្នុងការសំរេចថា ទឡ្ហីករណ៍ មិនបានអនុវត្តតាមវិធានលេខ ៦៣.៣ គឺស្ថិតនៅលើមេធាវីការពារក្តី ។ មេធាវីការពារក្តី បានខកខានក្នុងការដោះបន្ទុកនេះ ។

២៩. ដូចដែលបានចែងក្នុង វិធាន៧៧.១៣ អង្គបុរេជំនុំជម្រះ អាចច្រាលចោលសេចក្តីសំរេចរបស់សហចៅក្រមស៊ើបអង្កេត តែក្នុងករណី មានការយល់ព្រមដោយមតិភាគច្រើនលើសលុបរបស់ចៅក្រមតែប៉ុណ្ណោះ ។ ចំណុចនេះគួរតែយល់ដោយមានន័យថា ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត មិនត្រូវបានគេរំខានឡើយ ដរាបណាភាគីដែលប្តឹងឧទ្ធរណ៍ (ក្នុងករណីនេះ គឺមេធាវីការពារក្តី) អាចបញ្ចុះបញ្ចូលអង្គបុរេជំនុំជម្រះផ្សេងពីនេះ។ យុទ្ធសាស្ត្របែបនេះក៏ត្រូវបានអនុវត្តដោយ ICTY ផងដែរ ដោយសំរេចថា បន្ទុកនៃការកំណត់ថា មានកំហុសឆ្គងណាមួយដែលអាចរកឃើញទៅលើតុលាការជាន់ទាប នៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ត្រូវស្ថិតនៅលើភាគីដែលប្តឹងឧទ្ធរណ៍នោះ[11]។

៣០. ទោះបីជា អង្គបុរេជំនុំជម្រះ មិនយល់ស្របតាមគោលជំហររបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងបទដ្ឋាននៃការពិនិត្យសារឡើងវិញ ដូចមានចែងនៅក្នុងកថាខណ្ឌទី២៤ ដល់កថាខណ្ឌទី២៦ ខាងលើ ក៏ដោយក៏សុំឱ្យ អង្គបុរេជំនុំជម្រះ សំរេចថា ទឡ្ហីករណ៍ក្នុងការឃុំខ្លួនបណ្តោះអាសន្ន

[11] សូមអានផងដែរ *ព្រះរាជអាជ្ញា ទល់នឹង Popovic និង គូកន,* សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ជាអន្តរាគមន៍របស់អង្គជំនុំជម្រះសំរេចបដិសេធហេតុផលរបស់ Drago Nicolic សំរាប់សុំឱ្យមានការដោះលែងជាបណ្តោះអាសន្ន, សំណុំរឿងលេខ IT-05-88-AR65.1 សាលាឧទ្ធរណ៍នៃតុលាការ ICTY ចុះថ្ងៃទី២៤ មករា ២០០៦ កថាខណ្ឌ ៣។

បាននឹងកំពុងធ្វើឡើងស្របទៅតាមវិធាន ៦៣.៣ ជាដដែល។ បន្ទុកនៃការបង្ហាញថា ការឃុំខ្លួនបណ្ដោះអាសន្នមិនមែនជាវិធានការចាំបាច់តទៅទៀត គឺត្រូវស្ថិតនៅលើមេធាវីការពារក្ដី។ មេធាវីការពារក្ដី បានខកខានក្នុងការដោះបន្ទុកនេះ។

៣១. ទោះបីពុំមានសេចក្ដីណែនាំជាក់លាក់នៅក្នុងវិធានផ្ទៃក្នុង ឬច្បាប់ព្រហ្មទណ្ឌកម្ពុជា ក៏ដោយក៏ការអនុវត្តន៍ជាក់ស្ដែងដែលបានបង្កើតឡើងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺថា បន្ទុកនៃភស្តុតាងត្រូវស្ថិតនៅលើជនជាប់ចោទ[12]ដើម្បីធ្វើយុត្តិកម្មឱ្យតុលាការឃើញថា គាត់ពិតជាបានបំពេញទៅតាមលក្ខខណ្ឌយុត្តិកម្ម ដើម្បីទទួលបាននូវ "ការដោះលែងជាបណ្ដោះអាសន្ន"[13]។ ទោះបីករណីនីមួយៗ នឹងត្រូវសំរេចទៅតាមអង្គសេចក្ដីរបស់ខ្លួនក៏ដោយ ប៉ុន្តែការដោះលែងជាបណ្ដោះអាសន្ន តាមការអនុវត្តន៍ជាក់ស្ដែង កម្រនឹងផ្ដល់ឱ្យណាស់នៅចំពោះមុខតុលាការអន្តរជាតិ និងតុលាការអន្តរជាតូបនីយកម្មផ្សេងទៀត[14] ។

---

[12] សូមមើលឧទាហរណ៍ *ករណី ព្រះរាជអាជ្ញា ទល់នឹង Prlic et al.,* សេចក្ដីសំរេចលើបណ្ដឹងតវ៉ាសុំឱ្យ ពិចារណាឡើងវិញ បញ្ជាក់បំភ្លឺ និង សុំដោះលែង ព្រមទាំងពាក្យសុំបង្អង់អាជ្ញាយុកាលបណ្ដឹងឧទ្ធរណ៍ សំណុំរឿងលេខ IT-04-74-AR65 អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ ICTY ចុះថ្ងៃទី០៨ កញ្ញា ២០០៤ កថាខណ្ឌទី ២៨ ។ *ករណី ព្រះរាជអាជ្ញា ទល់នឹង Haradinaj* សេចក្ដីសំរេចលើបណ្ដឹងតវ៉ាសុំឱ្យដោះលែងជាបណ្ដោះអាសន្នរបស់ Ramush Haradinaj សំណុំរឿងលេខ IT-04-84-PT អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY ចុះថ្ងៃទី០៦ មិថុនា ២០០៥ កថាខណ្ឌទី ២១ ។ *ករណី ព្រះរាជអាជ្ញា ទល់នឹង Brdjanin និង Talic* សេចក្ដីសំរេចលើបណ្ដឹងតវ៉ាសុំឱ្យដោះលែងជាបណ្ដោះអាសន្ន ធ្វើឡើងដោយ Momir Talic សំណុំរឿងលេខ IT-99-36-T អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY ចុះថ្ងៃទី២៨ មីនា ២០១ កថាខណ្ឌទី ១៧ - ១៨ ។

[13] នៅ ICTY, ICTR និង SCSL ការបញ្ជាឱ្យដោះលែងអាចនឹងមាន ប្រសិនបើតុលាការមានការពេញចិត្តដោយយល់ថា ជនជាប់ចោទនឹងចូលបង្ហាញខ្លួននៅក្នុងពេលមានការជំនុំជម្រះ មិនបង្កឱ្យមានគ្រោះថ្នាក់ដល់ជនរង សាក្សី ឬបុគ្គលណាម្នាក់ ប្រសិនបើគាត់ត្រូវបានដោះលែង (វិធានទី៦៥ នៃវិធាន ស្ដីពីនីតិវិធី និងភស្តុតាងរបស់ ICTY, ICTR និង SCSL) ។

[14] ករណី ICTY៖ *ព្រះរាជអាជ្ញា ទល់នឹង Darko Madja* សេចក្ដីសំរេចលើសំណើសុំឱ្យដោះលែងជាបណ្ដោះអាសន្ន របស់ Darko Madja សំណុំរឿងលេខ IT-02-59-P អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY ចុះថ្ងៃទី១៥ មេសា ២០០២ កថាខណ្ឌទី ២៩ ។ *ករណី ព្រះរាជអាជ្ញា ទល់នឹង Mile Mrsic* សេចក្ដីសំរេចលើបណ្ដឹងឧទ្ធរណ៍ដែលប្រឆាំងនឹង ការបដិសេធន៍ មិនព្រមអនុញ្ញាតឱ្យដោះលែងជាបណ្ដោះអាសន្ន សំណុំរឿងលេខ IT-95-13/1-AR65 អង្គជំនុំជម្រះសាលាដំបូង របស់ ICTY ចុះថ្ងៃទី០៨ តុលា ២០០២ ។ *ព្រះរាជអាជ្ញា ទល់នឹង Pasko Ljubicic* សេចក្ដីសំរេចស្ដីលើការការពារបណ្ដឹងតវ៉ាសុំឱ្យដោះលែងជាបណ្ដោះអាសន្ន របស់ជនជាប់ចោទ សំណុំរឿងលេខ IT-00-41-PT អង្គជមនុំជម្រះសាលាដំបូងរបស់ ICTY ចុះថ្ងៃទី០២ សីហា ២០០២ ។ *ករណី ព្រះរាជអាជ្ញា ទល់នឹង Limaj et al.,* សេចក្ដីសំរេចលើបណ្ដឹងតវ៉ាសុំឱ្យដោះលែងជាបណ្ដោះអាសន្ន របស់ Fatmir Limaj សំណុំរឿងលេខ IT-03-66-PT អង្គជំនុំជម្រះសាលាដំបូង របស់ ICTY ចុះថ្ងៃទី១២ កញ្ញា ២០០៣ ។ ករណី SCSL៖ *ករណី ព្រះរាជអាជ្ញា ទល់នឹង Sesay et al.,* សេចក្ដីសំរេចលើបណ្ដឹងតវ៉ាសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ធ្វើឡើងដោយ Morris Kallon សំណុំរឿងលេខ ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងការឃុំខ្លួនបណ្ដោះអាសន្ន លើឈ្មោះ ឌុច

៣២. នៅក្រោមវិធានផ្ទៃក្នុង ពាក្យដែលថែងថា "ការឃុំខ្លួនបណ្តោះអាសន្ន" ត្រូវបានប្រើប្រាស់ជាជាងការប្រើពាក្យថា "ការដោះលែងជាបណ្តោះអាសន្ន" ។ ប៉ុន្តែ នៅ អ.វ.ត.ក ក៏ដូចជានៅតាមតុលាការផ្សេងទៀតដែរ ការពិចារណាដូចគ្នានេះអនុវត្តចំពោះការចោទប្រកាន់នៃ *"បទឧក្រិដ្ឋដែល ត្រូវថ្កោលទោសជាសកល (ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាម)"* ដូចដែលធ្លាប់បានធ្វើអាត្ថាធិប្បាយដោយអង្គជំនុំជម្រះតុលាការកំពូលរបស់ ICTY នៅក្នុងករណីរបស់ *Nikolic*[15] ។ សហគមន៍អន្តរជាតិមានសេចក្តីសង្ឃឹមថា ជនជាប់ចោទបទឧក្រិដ្ឋធ្ងន់ធ្ងរនៃការរំលោភច្បាប់មនុស្សធម៌អន្តរជាតិនឹងត្រូវនាំខ្លួនដើម្បីស្វែងរកយុត្តិធម៌។ ទោះបីគេតែងតែត្រូវថ្លឹងថ្លែងអំពីសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទយ៉ាងណាក្តី[16] កត្តានេះ គឺជារឿងតែមួយគត់ ដែលតុលាការត្រូវដោះស្រាយជាមួយនឹងកង្វល់របស់សហគមន៍អន្តរជាតិ ។ ដូចដែលបានទទួលស្គាល់នៅតុលាការពិសេសសំរាប់សារ៉ាឡេអូន នៅក្នុងករណីរបស់ *ព្រះរាជអាជ្ញា ទល់នឹង Issa Hasan Sesay*[17]៖

*"... គេត្រូវចងចាំក្នុងចិត្តថា តាមលក្ខណៈជាក់លាក់នៃតុលាការអន្តរជាតិ ឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការនេះ អាចនឹងត្រូវចាត់ទៅតាមប្រភេទឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត នៅក្រោមច្បាប់អន្តរជាតិ។ ហេតុដូចនេះ គេអាចនិយាយថា យុទ្ធសាស្ត្រដើម្បី*

---

SCSL-04-15-PT អង្គជំនុំជម្រះសាលាដំបូងរបស់ SCSL ចុះថ្ងៃទី២៣ កុម្ភៈ ២០០៤ កថាខណ្ឌទី ៣៥ ។ *ករណី ព្រះរាជអាជ្ញា ទល់នឹង Sam Hinga Norman* សេចក្តីសំរេចលើបណ្តឹងតវ៉ាសុំឱ្យធ្វើការកែប្រែលក្ខខណ្ឌនៃការឃុំឃាំង សំណុំរឿងលេខ SCSL-2003-08-PT ចុះថ្ងៃទី២៦ វិច្ឆិកា ២០០៣ កថាខណ្ឌទី ៨។ ការដោះលែងបណ្តោះអាសន្នមិនបានធ្លាប់ចេញឱ្យឡើយ មិនថា ICTR ឬតុលាការពិសេសសំរាប់សារ៉ាឡេអូន នោះទេ៖ សូមមើល Archbold, *តុលាការព្រហ្មទណ្ឌអន្តរជាតិ៖ ការអនុវត្តន៍ នីតិវិធី និងភស្តុតាង* (ទីក្រុងឡុង៖ Sweet and Maxwell 2005) វាក្យខ័ណ្ឌទី៧-១២៨ ទំព័រ ២៨៤។

[15] កថាខណ្ឌទី២៥ *Nikolic ព្រះរាជអាជ្ញា ទល់នឹង Dragan Nikolic* សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ លើបញ្ហាបន្ទាន់បន្តិ (Interlocutory Appeal) ទាក់ទិននឹង នីត្យាកូលភាពនៃការចាប់ខ្លួន សំណុំរឿងលេខ IT-94-2-AR73, ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី៥ មិថុនា ឆ្នាំ២០០៣ កថាខ័ណ្ឌទី២៥

[16] កថាខ័ណ្ឌទី២៥ *Nikolic ព្រះរាជអាជ្ញា ទល់នឹង Dragan Nikolic* សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ លើបញ្ហាបន្ទាន់បន្តិ (Interlocutory Appeal) ទាក់ទិននឹង នីត្យាកូលភាពនៃការចាប់ខ្លួន សំណុំរឿងលេខ IT-94-2-AR73, ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី៥ មិថុនា ឆ្នាំ២០០៣ កថាខ័ណ្ឌទី២៥

[17] *ករណី ព្រះរាជអាជ្ញា ទល់នឹង Issa Hassan Sesay* សេចក្តីសំរេចលើពាក្យសុំអោយដោះលែងជាបណ្តោះអាសន្នរបស់ ចុះថ្ងៃទី៣១ មីនា ២០០៤ TC, កថាខណ្ឌទី ៤០..

*បានការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលមានប្រើនៅក្នុងតុលាការជាតិដែលមានសមត្ថកិច្ច អាចនឹងមានភាពខុសគ្នាពីតុលាការអន្តរជាតិ"។*

៣៣. សហព្រះរាជអាជ្ញា សូមស្នើដាក់ជូន គោលការណ៍ណែនាំទាំងអស់នេះ ដើម្បីជាសេចក្តីណែនាំបន្ថែមដល់អង្គបុរេជំនុំជម្រះ។

## អង្គហេតុ
## មូលហេតុដែលត្រូវបានរកឃើញ

៣៤. ដូចបានកំណត់ដោយសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទត្រូវបានចោទប្រកាន់ នៅក្នុងចំណោមបញ្ហាផ្សេងទៀតថា *"...ដឹកនាំមន្ទីរសន្តិសុខ ស-២១ ដោយផ្ទាល់នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលនៅក្រោមសិទ្ធិអំណាចរបស់ខ្លួន មានការរំលោភបំពានច្រើនរាប់មិនអស់ ដែលបានចោទប្រកាន់ថាបានធ្វើឡើងប្រឆាំងនឹងជនស៊ីវិល (ការឃុំឃាំង អំពើធ្វើទារុណកម្មតាមទំនើងចិត្ត និងអំពើអមនុស្សធម៌ផ្សេងៗទៀត, ការសម្លាប់រង្គាល ។ល។) ដែលបានកើតឡើងនៅក្នុងបរិបទនយោបាយមួយនៃការរំលោភបំពានយ៉ាងទូលំទូលាយ និងជាប្រព័ន្ធ និងរួមផ្សំគ្នាបង្កើតបានជា បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ*[18] ។

៣៥. ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេត ស្របគ្នានឹងកថាខណ្ឌទី៤៩-៥៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបានចែងកំណត់យ៉ាងពិស្តារនូវ វិសាលភាពនៃអំពើឧក្រិដ្ឋនៅមន្ទីរស-២១ និង កថាខណ្ឌ ទី១០៤ - ១១៣ ដែលគូសបញ្ជាក់អំពីសិទ្ធិអំណាចរបស់ជនត្រូវចោទ ។ ការចោទប្រកាន់ទាំងអស់នេះ បានការគាំទ្រយ៉ាងពេញលេញតាមរយៈកសិណសាក្សី ដែលទទួលបានពីអតីតអ្នកនៅរស់រានមានជីវិត និងអតីតបុគ្គលិករបស់មន្ទីរ ស-២១ ។ ឯកសារមានចំនួនរាប់រយនៅក្នុងសំណុំរឿង ដែលបានដាក់ជូនដោយ សហព្រះរាជអាជ្ញា ជាការគាំទ្រចំពោះការចោទប្រកាន់ទាំងអស់នេះ ។ កំណត់ហេតុនៃកិច្ចប្រជុំ ទូរលេខ

---

[18] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ កថាខណ្ឌ ទី១ ។

ការធ្វើទំនាក់ទំនងរវាងជនត្រូវចោទនិងថ្នាក់លើ ហើយនឹងថ្នាក់ក្រោមរបស់ខ្លួន បញ្ជីឈ្មោះអ្នកទោស តារាងកាលវិភាគសំរាប់សួរចម្លើយ "ចម្លើយសារភាព" សរសេរដោយដៃ និងវាយជាអង្គុលីលេខដែលយកបានពីជនជាប់ឃុំឃាំងនៅក្រោមអំពើទារុណកម្ម បញ្ជីឈ្មោះអ្នកត្រូវសម្លាប់ និងរូបថតជាច្រើន បានលាតត្រដាងឲ្យឃើញអំពីភាពល្អិតល្អន់របស់មន្ទីរ ស-២១ និងពីរបៀបដែលមនុស្សជាង ១៤,០០០ នាក់ បានត្រូវសម្លាប់ នៅក្រោមការណែនាំដ៏ច្បាស់លាស់ និងសិទ្ធិអំណាចរបស់ជនត្រូវចោទ។

៣៦. មេធាវីការពារក្តី ពុំបានស្វែងរកការតវ៉ាទៅនឹងហេតុផលដែលថា សហចៅក្រមស៊ើបអង្កេតបានរកឃើញហេតុផលយ៉ាងល្អ ដែលអាចឲ្យជឿបានថា ជនត្រូវចោទ បានប្រព្រឹត្តបទឧក្រិដ្ឋដូចដែលបានចោទប្រកាន់នៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះឡើយ ។ ជនត្រូវចោទបានសារភាពថា តាមការពិត គាត់គឺជាអនុប្រធាន និងបន្ទាប់មកជាប្រធានមន្ទីរ ស-២១ យ៉ាងហោចណាស់ចាប់ពីឆ្នាំ១៩៧៥ រហូតមក។ ប៉ុន្តែ នៅក្នុងបទធ្វើសម្ភាសន៍របស់គាត់ជាមួយសហចៅក្រមស៊ើបអង្កេត មកដល់ពេលសព្វថ្ងៃនេះ គាត់បានព្យាយាមផ្តាច់ខ្លួនគាត់ចេញពីការទទួលខុសត្រូវណាមួយ ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅទីនោះ។ គាត់តវ៉ាថា សិទ្ធិអំណាចរបស់គាត់ គឺមានតែក្នុងទ្រឹស្តី មិនមាននៅក្នុងការពិតជាក់ស្តែងទេ និងថា តួនាទីរបស់គាត់គ្រាន់តែជាអ្នកនាំព័ត៌មានពីថ្នាក់លើនៅក្នុងគណបក្សរបស់គាត់ ទៅអ្នកនៅថ្នាក់ក្រោមរបស់គាត់នៅ មន្ទីរស-២១ តែប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញា មិនទទួលយកអំណះអំណាងរបស់ជនត្រូវចោទទេ ។

## ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការមួយដ៏ចាំបាច់

៣៧. នៅក្នុងកថាខណ្ឌទី ១១៨.ក - ១១៨.ឃ នៃ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងនៅក្នុងកិច្ចពិភាក្សាដេញដោល ធ្វើឡើងកាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញាបានស្នើឲ្យសំរេចថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការមួយដ៏ចាំបាច់ ស្របតាមទម្លិករណ៍ចំនួនបួនផ្សេងៗគ្នា ។ ភស្តុតាងគាំទ្រនៃការសំរេចនេះ បានបង្ហាញយ៉ាងទូលំទូលាយនៅក្នុងសំណុំរឿងនិងនៅក្នុងសារណា ធ្វើឡើងកាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ។

សហចៅក្រមស៊ើបអង្កេត បានបង្គាប់ឲ្យធ្វើការឃុំខ្លួនបណ្ដោះអាសន្ន ចំពោះជនត្រូវចោទ ទៅតាម ទឡ្ហីករណ៍ចំនួនបី ក្នុងចំណោមទឡ្ហីករណ៍ទាំងបួន ដូចខាងក្រោម៖

### *ទឡ្ហីករណ៍ ទី១*

### *<u>ការធានាអំពីវត្តមានរបស់ជនត្រូវចោទ (វិធាន ៦៣.៣.ខ.៣)</u>*

៣៨. សហចៅក្រមស៊ើបអង្កេត បានកំណត់ថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការចាំបាច់ ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទ អាស្រ័យដោយទម្ងន់នៃបទល្មើស ដែលបានចោទប្រកាន់ និងភាពធ្ងន់ធ្ងរនៃការប្រកាសទោសណាមួយ ប្រសិនបើត្រូវបានកាត់ទោស[19] ។

៣៩. សហព្រះរាជអាជ្ញា យល់ព្រមតាមការសំរេចនេះដែលថា ទម្ងន់នៃបទល្មើស និងភាពធ្ងន់ធ្ងរនៃការប្រកាសទោសជាសក្ដានុពល ពាក់ព័ន្ធទៅនឹងការវាយតម្លៃអំពីហានិភ័យនៃការគេចខ្លួន នៅពេលពិចារណាជាមួយកត្តាផ្សេងៗទៀតទាំងអស់នៅក្នុងករណីនេះ។ នេះជាភាពស្របគ្នាទៅនឹងយុត្តិសាស្ត្រ ទាំងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ទាំង តុលាការ ICTY[20] ។

---

[19] ដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ កថាខ័ណ្ឌទី២២..

[20] សូមមើល៖ *ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ករណី ព្រះរាជអាជ្ញា ទល់នឹង Thomas Lubanga Dyilo,* សេចក្ដីសំរេចលើពាក្យសុំដោះលែងជាបណ្ដោះអាសន្ន ដល់ឈ្មោះ Thomas Lubanga Dyilo សំណុំរឿងលេខ 01/04-01/06 ចៅក្រម ICC តែមួយរូបគត់ ចុះថ្ងៃទី១៨ តុលា ២០០៦ ទំព័រទី ៥-៦ ។ សូមមើលផងដែរ *ករណី ព្រះរាជអាជ្ញា ទល់នឹង Mico Stanisic* សេចក្ដីសំរេចលើបណ្ដឹងតវ៉ាសុំឱ្យដោះលែងជាបណ្ដោះអាសន្ន របស់ Miko Stanisic សំណុំរឿងលេខ IT-04-79-PT អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY ចុះថ្ងៃទី១៩ កក្កដា ២០០៥ កថាខណ្ឌទី ៨-៩ ។ *ករណី ព្រះរាជអាជ្ញា ទល់នឹង Cermak និង Markac* សេចក្ដីសំរេចលើបណ្ដឹងឧទ្ធរណ៍ លើបញ្ហាបន្ទាន់បង្ហំ (Interlocutory Appeal) ប្រឆាំងនឹងសេចក្ដីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបដិសេធមិនព្រមឱ្យដោះលែងជាបណ្ដោះអាសន្ន សំណុំរឿងលេខ IT-03-73-AR 65.1 អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ ICTY ចុះថ្ងៃទី០២ ធ្នូ ២០០៤ កថាខណ្ឌទី ២៥ ។ *ករណី ព្រះរាជអាជ្ញា ទល់នឹង Limaj et al.,* សេចក្ដីសំរេចលើបណ្ដឹងតវ៉ាសុំឱ្យដោះលែងជាបណ្ដោះអាសន្នរបស់ Haradin Bala សំណុំរឿងលេខ IT-03-66-AR 65.2 អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY ចុះថ្ងៃទី១៦ កញ្ញា ២០០៣ ទំព័រទី ៥ ។ *ករណី ព្រះរាជអាជ្ញា ទល់នឹង Brdjanin* សំណុំរឿងលេខ IT-99-36-T សេចក្ដីសំរេចលើបណ្ដឹងតវ៉ាសុំឱ្យ ដោះលែងជាបណ្ដោះអាសន្ន ធ្វើឡើងដោយ Radoslav Brdjanin សំណុំរឿងលេខ IT-99-36-T អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY ចុះថ្ងៃទី២៥ កក្កដា ២០០០ កថាខណ្ឌទី ១៦ ។ *ករណី Seselj* សេចក្ដីសំរេចលើញត្តិរបស់មេធាវីការពារក្ដី ស្នើសុំឱ្យដោះលែងជាបណ្ដោះអាសន្ន សំណុំរឿងលេខ IT-03-67-PT អង្គជំនុំជម្រះ II ចុះថ្ងៃទី២៣ កក្កដា ២០០៤ កថាខណ្ឌទី៩។

00154577



៤០. ដូចសហព្រះរាជអាជ្ញាធ្លាប់បានទាញហេតុផលនៅក្នុងសវនាការតទល់ និង តាមប្រវេសន៍[21] (ការទទួលទុកជាត្រូវ) របស់ខ្លួនថា ចាប់ពីឆ្នាំ១៩៧៩ រហូតដល់ពេលការចាប់ខ្លួនរបស់គាត់ក្នុងឆ្នាំ១៩៩៩ ជនត្រូវចោទបានផ្លាស់ប្តូរឈ្មោះរបស់ខ្លួនជាបន្តបន្ទាប់។ តាមការពិត គាត់បានបាត់ខ្លួនទាំងស្រុងចេញពីសាធារណៈមតិ។ គាត់បានផ្លាស់ប្តូរទីតាំង និងទីកន្លែងការងាររបស់ខ្លួនជាបន្តបន្ទាប់[22] ។ គាត់មិនបានរក្សាទំនាក់ទំនងជាមួយសាជិកគ្រួសារជិតស្និតរបស់គាត់ទេ និងសូម្បីតែម្តាយរបស់គាត់ក៏បានគិតថា គាត់បានស្លាប់ទៅហើយដែរ[23] ។ គាត់បានព្យាយាមធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីលាក់កំបាំងអតីកាលរបស់គាត់។

៤១. ជនត្រូវចោទ អះអាងថាគាត់ "បានរៀបចំខ្លួនរួចជាស្រេចដើម្បីលាតត្រដាងបទឧក្រិដ្ឋរបស់ខ្មែរក្រហម" ហើយចំណុចនេះ មិនមែនគ្មានហានិភ័យនៃការរត់គេចខ្លួននោះទេ ។ អង្គបុរេជំនុំជម្រះ មិនគួរភ្ជាប់ទម្ងន់ណាមួយទៅនឹងចំណុចនេះទេ។ តាមការសម្ភាសន៍របស់គាត់មកដល់ពេលនេះ ជនត្រូវចោទហាក់ដូចជាមិនមានឆន្ទៈទទួលស្គាល់ទាំងការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់គាត់ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅ មន្ទីរស-២១ ទាំងវិសាលភាពនៃសិទ្ធិអំណាចដ៏ពេញលេញរបស់គាត់ក្នុងនាមជាប្រធាននៃមន្ទីរឃុំឃាំងនេះ[24] ។

---

[21] កំណត់ហេតុជាភាសាអង់គ្លេស (*procès verbal)* ចុះថ្ងៃទី២៣ សីហា ២០០៧ ទំព័រទី៨។ សូមមើលផងដែរ Seth Sydans *"អ្នកធ្វើទារុណកម្មមកលើគេ នៃរបបខ្មែរក្រហមបានផ្លាស់ប្តូរ មានអារម្មណ៍ថា ជីវិតរបស់ខ្លួនដូចជីវិតរបស់ St Paul" The Seattle Times* ចុះថ្ងៃទី២ ឧសភា ១៩៩៩ (សូមមើល ឯកសារបន្ថែម ក)។

[22] ក្នុងពេលមួយ នៅពេលគាត់កំពុងធ្វើការនៅស្រុកស្វាយចេក ជនត្រូវចោទត្រូវបានស្គាល់ថា ជាអតីតប្រធានមន្ទី ស-២១។ គាត់បានស្វែងរកកន្លែងថ្មី និងបានផ្លាស់ទៅរស់នៅស្រុកសំឡូត ដែលជាតំបន់មួយត្រូវបានគេស្គាល់ថា តំបន់ពួកក្បាលរឹងខ្មែរក្រហម ជាទីកន្លែងដែលពេលក្រោយមកគាត់បានប្រាប់អ្នកកាសែតម្នាក់ថា "មានមនុស្សជួយការពារខ្ញុំ" សៀវភៅរបស់ Nic Dunlop, ដែលមានចំណងជើងថា *The Lost executioner* (អ្នកពិឃាតដែលបាត់ខ្លួន) *រឿងរបស់ខ្មែរក្រហម* (សូមមើល ឯកសារបន្ថែម ខ) ទំព័រ ២៥២។ សូមមើលផងដែរ Seth Sydans *"អ្នកធ្វើទារុណកម្មមកលើគេ នៃរបបខ្មែរក្រហមបានផ្លាស់ប្តូរ មានអារម្មណ៍ថា ជីវិតរបស់ខ្លួនដូចជីវិតរបស់ St Paul" The Seattle Times* ចុះថ្ងៃទី២ ឧសភា ១៩៩៩ (សូមមើលឯកសារបន្ថែម ក)។

[23] ការផ្សាយតាមប្រព័ន្ធឃោសនាព័ត៌មាន ដោយ DC-Cam "ស្វែងរកការពិត" ការបោះពុម្ពផ្សាយពិសេសជាភាសាអង់គ្លេស ខែកក្កដា ឆ្នាំ ២០០៣ ទំព័រ ៣៦ (ERN 00080431) (សូមើលឯកសារបន្ថែម គ)។

[24] កំណត់ហេតុជាភាសាអង់គ្លេស (*procès verbal)* ៧ សីហា ២០០៧ "អ្នកដែលនៅពីក្រោមបញ្ជារបស់ខ្ញុំ ខ្ញុំបានបំភ្លេចចោលអស់ហើយ" (ទំ័ពរ៣); "ខ្ញុំមិនបានធ្វើអ្វីៗដោយឯកឯងទេ" (ទំព័រ ៤); ២៣ សីហា ឆ្នាំ២០០៧៖ ការពិត ហ៊ំ ជាអ្នកទទួលខុសត្រូវនៅ ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងការឃុំខ្លួនបណ្តោះអាសន្ន លើឈ្មោះ ឌុច

៤២. មេធាវីរបស់ជនត្រូវចោទ លោក ការ សាវុត្ថ បានចង្អុលបង្ហាញថា "ខ្លួនគាត់ផ្ទាល់ជាអ្នកធានា" អំពីវត្តមានរបស់កូនក្តីរបស់ខ្លួន ក្នុងពេលមានសវនាការនៅពេលអនាគត ប្រសិនបើកូនក្តីរបស់គាត់ត្រូវបានដោះលែង ។ ចំណុចនេះមិនច្បាស់ថា តើមានមូលដ្ឋានណាដែលត្រូវផ្តល់សំរាប់ការធានាបែបនេះ និងចំណាត់ការណាខ្លះដែលត្រូវយកមកអនុវត្ត ប្រសិនបើជនត្រូវចោទខកខានក្នុងការចូលខ្លួនបង្ហាញវត្តមាន ប្រសិនបើគាត់ត្រូវបានដោះលែងមែននោះ ។ ហេតុដូច្នេះ សូមអង្គបុរេជំនុំជម្រះសំរេចថា ការអនុវត្តន៍បែបនេះមិនសមស្របឡើយ សំរាប់ឧក្រិដ្ឋកម្ម ដែលកំពុងស្ថិតនៅក្រោមការពិចារណាដោយ អ.វ.ត.ក ។

៤៣. ហេតុដូច្នេះ ដោយសារហេតុផលទាំងអស់នេះហើយ គ្មាន "កំហុសឆ្គងដែលអាចរកឃើញ" នៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងការសំរេចលើការឃុំខ្លួនបណ្តោះអាសន្នដែលជាវិធានការចាំបាច់ ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទ ឡើយ។ ក្រៅពីនេះ មេធាវីការពារក្តី បានខកខាននៅក្នុងការបង្ហាញថា វត្តមានរបស់ជនត្រូវចោទនឹងត្រូវបានធានានៅក្នុងដំណើរការនីតិវិធី ប្រសិនបើគាត់ត្រូវបានដោះលែង។

## *ទឡ្ហីករណ៍ ទី២*

## <u>ការការពារសន្តិសុខឱ្យជនត្រូវចោទ (វិធាន ៦៣.៣.ខ.៤)</u>

៤៤. សហចៅក្រមស៊ើបអង្កេត បានកំណត់ថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ ។ សហចៅក្រមស៊ើបអង្កេតបានផ្តល់ហេតុផលថា ការដោះលែងរូបគាត់ "ប្រថុយនឹងគ្រោះថ្នាក់នៃការញុះញង់... ប្រឆាំងតវ៉ាដោយសារការឈឺចិត្ត/តូចចិត្តដែលអាចនាំឱ្យមានអំពើហិង្សា និងប្រហែលជាអាចធ្វើឱ្យមានគ្រោះថ្នាក់ ដល់សុវត្ថិភាពរបស់បុគ្គលដែលពាក់ព័ន្ធ"[25] ។

---

ទីក្រុងភ្នំពេញ" (ទំព័រ ៦); "ខ្ញុំជាប្រធានដែលគ្មានអំណាច...មិនដែលធ្លាប់ធ្វើការសំរេចដោយខ្លួនឯងទេ... តួនាទីរបស់ខ្ញុំគ្រាន់តែជាអ្នកបញ្ជូនបញ្ហាតែប៉ុណ្ណោះ... ខ្ញុំគ្រាន់តែជាប្រធានក្នុងទ្រឹស្តី" (ទំព័រ៧)។

[25] ដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ កថាខណ្ឌទី២២

00154579



៤៥. សហព្រះរាជអាជ្ញា យល់ព្រមតាមការសំរេចនេះដែលថា សុវត្ថិភាពរបស់ជនត្រូវចោទអាចនឹងមានគ្រោះថ្នាក់ ប្រសិនបើគាត់ត្រូវបានដោះលែង។ តាំងពីបានរកឃើញគាត់នៅក្នុងឆ្នាំ១៩៩៩ ដោយអ្នកកាសែតបច្ចិមប្រទេសមក ជនត្រូវចោទ បានផ្តល់នូវបទសម្ភាសន៍[26] ជាច្រើនទាក់ទិននឹងសកម្មភាពរបស់គាត់ នៅក្នុងរបបកម្ពុជាប្រជាប្រជាធិបតេយ្យ ។ គាត់បានអះអាងឡើងវិញអំពីមុខតំណែងជាន់ខ្ពស់របស់គាត់ជាប្រធាន មន្ទីរស-២១។ គាត់ថែមទាំងបានជាប់ជំពាក់ជាមួយនឹងមេដឹកនាំជាន់ខ្ពស់បំផុត និងអ្នកផ្សេងទៀត លើការទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋ ។ ក្នុងអំឡុងពេលនៃការធ្វើសម្ភាសន៍ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទបានអះអាងអំពីអត្ថិភាពនៃ មន្ទីរស-២១ និងមុខតំណែងរបស់គាត់ជាប្រធាន ។ គាត់បាននិយាយជៀមដាមចំពោះមុខតំណែងដ៏សំខាន់របស់ខ្លួន នៅក្នុងប្រព័ន្ធសន្តិសុខនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ គាត់បានអះអាងថា មេដឹកនាំជាន់ខ្ពស់នៃរបបនេះបានដឹងអំពីអត្ថិភាពរបស់ខ្លួន និងអំពើគោលបំណងរបស់ខ្លួន[27]។

៤៦. ភស្តុតាងដែលបានដាក់ជូននៅក្នុងសំណុំរឿង គាំទ្រដល់ការសន្និដ្ឋានដែលថា សន្តិសុខរបស់ជនត្រូវចោទ នឹងជួបគ្រោះថ្នាក់ប្រសិនបើគាត់ត្រូវបានដោះលែង ។ ជនត្រូវចោទខ្លួនឯងផ្ទាល់បានទទួលស្គាល់ នូវគ្រោះថ្នាក់ចំពោះសន្តិសុខផ្ទាល់ខ្លួនរបស់គាត់ ពេលគាត់និយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ តាមរយៈការរកឃើញដោយអ្នកកាសែតបស្ចិមប្រទេសក្នុងឆ្នាំ១៩៩៩ បានរាយការណ៍ឲ្យដឹងថា គាត់ "ច្បាស់ណាស់ថាមានការភ័យខ្លាច ចំពោះជីវិតរបស់គាត់" ។ គាត់

[26] សូមមើលជាពិសេស បទសម្ភាសន៍ជាមួយការិយាល័យ UNHCHR, នៅថ្ងៃទី៤-៦ ខែមិថុនា ឆ្នាំ១៩៩៩ លេខ ERN 00002494-00002557 (សូមមើលឯកសារបន្ថែម ឃ)។ សូមមើលការសម្ភាសន៍ធ្វើឡើងដោយ ណាត ថាយ័រ និង Nic Dunlop, ដែលបានរាយការណ៍នៅក្នុងអត្ថបទចុះផ្សាយទាំងពីរដោយ ណាត ថាយ័រ នៅក្នុង the *Far Eastern Economic Review* ចុះផ្សាយថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩ "Death in Detail" (ERN 00087513- 00087514) (សូមមើលឯកសារបន្ថែម ង) និង "ខ្ញុំកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់" (សូមមើលឯកសារបន្ថែម ច) និងសៀវភៅរបស់ Nic Dunlop, ដែលមានចំណងជើងថា *The Lost executioner* (អ្នកពិឃាតដែលបាត់ខ្លួន)ៈ *រឿងរបស់ខ្មែរក្រហម* (Bloomshury: 2005) ទំព័រ២៧០-២៧៨ (សូមមើល ឯកសារបន្ថែម ខ)។

[27] ជាឧទាហរណ៍ សូមមើល កំណត់ហេតុជាភាសាអង់គ្លេស (*procès verbal)* ចុះថ្ងៃទី៧ សីហា ឆ្នាំ២០០៧ (ជាពិសេសទំព័រ៥ និង៦) កំណត់ហេតុជាភាសាអង់គ្លេស (*procès verbal)* ចុះថ្ងៃទី២៣ សីហា ២០០៧ (ជាពិសេសទំព័រទី៣ ទំព័រទី៥ និងទំព័រទី៩) និង កំណត់ហេតុជាភាសាអង់គ្លេស (*procès verbal)* ចុះថ្ងៃទី៥ ខែកញ្ញា ២០០៧ (ជាពិសេសទំព័រទី៥ ទំព័រទី៦ និងទំព័រទី៧)

តែងនិយាយខ្សឹបៗប្រាប់អ្នកកាសែត និងនៅពេលខ្លះទៀត គាត់សុំឲ្យគេយកគាត់ទៅតំបន់ដែលគ្មានអ្នកណាអាចដឹងបាន[28] ។ នៅក្នុងបទសម្ភាសន៍ផ្សេងទៀត ធ្វើឡើងជាមួយអ្នកកាសែតដដែល គាត់បានសារភាពមុនការចាប់ខ្លួនថា "ខ្ញុំខ្លាចមនុស្សនៅជុំវិញខ្លួនខ្ញុំ ។ ខ្ញុំមិនដឹងថា អ្នកណាជាមនុស្សរបស់ នួន ជា របស់តា ម៉ុក របស់ខៀវ សំផន ទេ ។ ខ្ញុំកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ ។ ជីវិតរបស់ខ្ញុំកំពុងជួបគ្រោះថ្នាក់... ពួកគេអាចសម្លាប់ខ្ញុំ"[29] ។

៤៧. អំពើគំរាមកំហែងដែលបានធ្វើមកលើជនត្រូវចោទដោយជនសង្ស័យផ្សេងទៀត ត្រូវបានទទួលស្គាល់ជាអន្តរជាតិ ។ លោក Thomas Hammerberg អតីតតំណាងពិសេសរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំប្រទេសកម្ពុជា បានបញ្ជាក់អំពីក្ដីកង្វល់របស់គាត់[30] ។ អង្គការលើកលែងទោសអន្តរជាតិ បានបញ្ចេញ "ប្រតិកម្មជាបន្ទាន់" នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៩៩ ដែលនៅក្នុងប្រតិកម្មនេះ ពួកគេបានពិចារណាថា ជនត្រូវចោទ "អាចនឹងត្រូវសម្លាប់បំបិទមាត់ ដើម្បីកុំឲ្យឆ្លើយដាក់/ធ្វើកសិណប្រឆាំងនឹងអ្នកផ្សេង ដែលបានជាប់ពាក់ព័ន្ធនៅក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ"[31] ។

៤៨. អំពើគំរាមកំហែងទៅលើសន្តិសុខរបស់ជនត្រូវចោទ អាចនឹងធ្វើដោយជនរងគ្រោះ ឬ ក្រុមគ្រួសាររបស់ពួកគេផងដែរ ។ ក្នុងនាមអតីតជាប្រធានមន្ទីរស-២១ គាត់អាចទំនងជាមុខសញ្ញានៃការវាយប្រហារ សំរាប់ជនទាំងឡាយណាដែលស្វែងរកការសងសឹក ។ នៅក្នុង

---

[28] ណាត ថាយ័រ នៅក្នុង *Far Eastern Economic Review* ចុះផ្សាយថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩ (ERN 00087513-00087514) (សូមមើលឯកសារបន្ថែម ង) ។

[29] សូមមើល ណាត ថាយ័រ នៅក្នុង *Far Eastern Economic Review* ចុះផ្សាយថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩ (ERN 00087513-00087514) (សូមមើលឯកសារបន្ថែម ង)។ "ខ្ញុំកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់"៖ "ខ្ញុំមិនចង់ឲ្យមនុស្សណាម្នាក់ដឹងពី (ឌុច និង ណាត ថាយ័រ) ទំនាក់ទំនងរបស់យើងទេ... ព្រោះពួកគេអាចធ្វើឲ្យខ្ញុំគ្មានសុវត្ថិភាព... ខ្ញុំខ្លាចមនុស្សនៅជុំវិញខ្លួនខ្ញុំ។ ខ្ញុំមិនដឹងថា អ្នកណាខ្លះជាមនុស្សរបស់នួន ជា របស់ខៀវ សំផន ទេ ។ ជីវិតខ្ញុំកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ ... ពួកគេអាចសម្លាប់ខ្ញុំបាន ។ ពួកគេនឹងនិយាយថាខ្ញុំជាមនុស្សរបស់ CIA ដែលលក់ខ្លួនឲ្យអាមេរិក" (សូមមើលឯកសារបន្ថែម ច)។

[30] សូមមើល ណាត ថាយ័រ នៅក្នុង *Far Eastern Economic Review* ចុះផ្សាយថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩ (ERN 00087513-00087514) (សូមមើលឯកសារបន្ថែម ង) ។

[31] សូមមើល សកម្មភាពជាបន្ទាន់របស់ អង្គការលើកលែងទោស ៨៣/៩៩ "ការភ័យខ្លាចចំពោះសុវត្ថិភាព" ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៩ លេខ AI Index ASA 23/08/99 (សូមមើលឯកសារបន្ថែម ឆ) ។

ប្រទេសកម្ពុជា ការគំរាមកំហែងបែបនេះគឺអាចឱ្យជឿបាន ។ ដូចដែលធ្លាប់បានសង្កេតនៅក្នុងតុលាការពិសេសសេរ៉ាឡេអូន ជាទីកន្លែងដែលតុលាការស្ថិតនៅដោយផ្ទាល់ក្នុងទឹកដីមួយដែលឧក្រិដ្ឋកម្មដែលបានចោទត្រូវបានប្រព្រឹត្តឡើង មានចំណុចរសើបពិសេសដែលត្រូវចងចាំក្នុងចិត្ត នៅពេលណាតុលាការពិចារណាអំពីការដោះលែងជនជាប់ចោទណាម្នាក់[32] ។

៤៩. សហព្រះរាជអាជ្ញា សូមដាក់ជូនថា ការកន្លងផុតនៃពេលវេលា មិនបានលុបបំបាត់ចោលនូវភាពពាក់ព័ន្ធនៃ អំពើគំរាមកំហែងចំពោះជនត្រូវចោទនោះឡើយ។ ជាច្រើនឆ្នាំនៅក្រោយកិច្ចចរចា ឥឡូវនេះ អ.វ.ត.ក គឺជាការពិតហើយ។ ការចាប់ផ្តើមប្រតិបត្តិការរបស់តុលាការ មានការជាប់ជំពាក់យ៉ាងសំខាន់ទៅនឹងសន្តិសុខរបស់ជនត្រូវចោទ។ ការចូលបង្ហាញខ្លួនក្នុងពេលថ្មីៗនេះរបស់គាត់ចំពោះមុខសហចៅក្រមស៊ើបអង្កេត មានបង្កើតឱ្យមានចំណាប់អារម្មណ៍ជាបន្ទាន់ ដល់ប្រព័ន្ធឃោសនាព័ត៌មាន។ រូបថតថ្មីៗរបស់គាត់ បានបង្ហាញឱ្យឃើញយ៉ាងជាក់ស្តែងនៅលើកាសែត និងនៅតាមស្ថានីយទូរទស្សន៍របស់កម្ពុជា ។ បើទោះបីជាគាត់បានចំណាយពេលជាច្រើនឆ្នាំដោយប្រើឈ្មោះផ្សេងក៏ដោយ ឥឡូវនេះក្នុងប្រទេសទាំងមូល បានស្គាល់គាត់ និងបានដឹងអំពីការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ ។ មេធាវីបានលើកឡើងថាគ្មានការវាយប្រហារមកលើសុវត្ថិភាពផ្ទាល់ខ្លួនរបស់ជនត្រូវចោទឡើយ នៅចន្លោះឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៩ ។ ការផ្តល់នេះមិនមានការភ្ញាក់ផ្អើលឡើយ ដោយគ្រាន់តែបង្ហាញអំពីការផ្លាស់ប្តូរឈ្មោះយ៉ាងច្រើនអំពីការងារ និងទីកន្លែងនោះ ។ ប៉ុន្តែ ក្នុងចិត្តគំនិតរបស់ប្រជាពលរដ្ឋកម្ពុជា ឥឡូវនេះនិយាយជារួម គាត់ត្រូវបានភ្ជាប់ទៅនឹងរបបខ្មែរក្រហម និងនិយាយដោយឡែក បទឧក្រិដ្ឋនៅ មន្ទីរស-២១ ។ រាល់សេចក្តីដែលបានធ្វើឡើងដោយ អ.វ.ត.ក ទាក់ទងនឹងករណីរបស់គាត់ ត្រូវបានលើកយកទៅចុះផ្សាយយ៉ាងទូលំទូលាយដោយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។ ការដោះលែងណាមួយនៃជនត្រូវចោទ នឹងមិនត្រឹមតែបង្កើតឱ្យមានចំណាប់អារម្មណ៍របស់មហាជនប៉ុណ្ណោះទេ ប៉ុន្តែវានឹងបង្កឱ្យមានគ្រោះថ្នាក់យ៉ាងពិតប្រាកដ សំរាប់សុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ ដោយសារក្នុងពេលនេះ តាមអ្វីដែលគេគ្រប់គ្នានៅកម្ពុជាបានដឹងយ៉ាងទូលំទូលាយ អំពីការចោទប្រកាន់មកលើរូបគាត់ ។

---

[32] *ករណី ព្រះរាជអាជ្ញា ទល់នឹង Issa Hassan Sesay* សេចក្តីសំរេចលើពាក្យសុំអោយដោះលែងជាបណ្តោះអាសន្នរបស់ Issa essay សំណុំរឿងលេខ SCSL-04-15-PT អង្គជំនុំជម្រះសាលាដំបូងរបស់ SCSL ចុះថ្ងៃទី៣១ មីនា ២០០៤ កឋាខណ្ឌទី ៥៥ ។

៥០. ហេតុដូច្នេះ ដោយសារហេតុផលទាំងអស់នេះហើយ គ្មាន "កំហុសឆ្គងដែលអាចរកឃើញ" នៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងការសំរេចលើការឃុំខ្លួនបណ្តោះអាសន្នដែលជាវិធានការចាំបាច់ ដើម្បីធានាសន្តិសុខផ្ទាល់ខ្លួនរបស់ជនត្រូវចោទឡើយ ។ ក្រៅពីនេះ មេធាវីការពារក្តី បានខកខាននៅក្នុងការបង្ហាញថា នឹងគ្មានគ្រោះថ្នាក់ណាមួយនឹងកើតឡើងចំពោះជនត្រូវចោទឡើយ ប្រសិនបើគាត់ត្រូវបានដោះលែង។

## *ទឡ្ហីករណ៍ ទី៣*

## <u>ការរក្សាសណ្តាប់ធ្នាប់សាធារណៈ (វិធាន ៦៣.៣.ខ.៥)</u>

៥១. សហចៅក្រមស៊ើបអង្កេត បានកំណត់ថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ កំណត់ទៅតាម "បរិបទសង្គមកម្ពុជាដ៏ផុយស្រួយនៅក្នុងពេលបច្ចុប្បន្ន"[33] ជាកត្តាមួយដែលពាក់ព័ន្ធ ។

៥២. សហព្រះរាជអាជ្ញា យល់ព្រមតាមការសំរេចថា ការដោះលែងរូបគាត់ ប្រថុយនឹងគ្រោះថ្នាក់នៃការញុះញង់បង្កឲ្យមាន "ការប្រឆាំងតវ៉ាដោយសារការឈឺចិត្ត ដែលអាចនាំឲ្យមានអំពើហិង្សា"[34] ។ គេពុំដែលមានការជំនុំជម្រះទៅលើជនសង្ស័យណាម្នាក់ចំពោះបទល្មើសណាមួយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះឡើយ ដែលប្រជាពលរដ្ឋប្រមាណជា ១ភាគ៤ នៃប្រជាជនសរុបត្រូវបានស្លាប់ ។ ការចាប់ផ្តើមសកម្មភាពរបស់តុលាការ ធ្វើឡើងនៅចំពោះមុខ អ.វ.ត.ក អាចនឹងធ្វើឲ្យមានហានិភ័យដល់សង្គមកម្ពុជា[35] ។

---

[33] ដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ កថាខណ្ឌទី២២..

[34] ដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ កថាខណ្ឌទី២២..

[35] សូមមើលផងដែរ ឯកសាររបស់ Geerteke Jansen, *Voice from Takeo (សម្លេងពីខេត្ត តាកែវ)០:* ការសាកល្បងវាយតម្លៃអំពីការភ័យខ្លាច ទាក់ទិននឹងសាក្សីដែលអាចរកបានសំរាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ភ្នំពេញ: មជ្ឈមណ្ឌលឯកសារកម្ពុជា តុលា ឆ្នាំ២០០៦) (សូមមើលឯកសារបន្ថែម ជ) ។

00154583



៥៣. មេធាវីការពារក្តី បានទាញហេតុផលថា ៣០ឆ្នាំ នៅក្រោយការកើតឡើងនៃអង្គហេតុ ដែលថាបញ្ហានេះ គឺលែងមានការពាក់ព័ន្ធគ្នាអ្វីតទៅទៀតហើយ អំពីភាពគ្រោះថ្នាក់ដែលអាចធ្វើឱ្យខូចរបៀបរៀបរយនេះ ។ ការអះអាងនេះ ត្រូវបានជំទាស់ដោយសហព្រះរាជអាជ្ញា ។ ផលប៉ះពាល់នៃឧក្រិដ្ឋកម្មជាប្រព័ន្ធ នៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាជាង ១.៧ លាននាក់ស្លាប់ នៅបន្តរហូតមកដល់សព្វថ្ងៃនេះ ។ វេទិកាសាធារណៈ និងគំរោងកម្មវិធីផ្សព្វផ្សាយសហគមន៍ ក្នុងក្តីសង្ឃឹមអំពីការជំនុំជម្រះនេះ បានជួយលើស្ទួយដល់ការយល់ដឹងរបស់សាធារណៈជនកាន់តែច្រើនឡើងថែមទៀត ។ ក្តីសង្ឃឹមរបស់សាធារណៈជន មានកំរិតខ្ពស់ណាស់ ។ វាទំនងជានឹងមានការកើនឡើងនៃ ភាពគ្រោះថ្នាក់ដែលអាចកើតចេញពីស្ថានភាពមួយដែលងាយនឹងផ្លាស់ប្តូរ និងដែលមិនអាចស្មានទុកជាមុនបាន ក្នុងខណៈដែលអនុស្សាវរីយ៍ និងការឈឺចាប់ ត្រូវបានចាប់ផ្តើមឡើងវិញតាមរយៈការចាប់ផ្តើមដំណើរការរបស់ អ.វ.ត.ក ។ វាក៏ទំនងផងដែរថា នឹងមានប្រតិកម្មជាអវិជ្ជមាន នៅក្នុងចំណោមប្រជាជន ចំពោះការដោះលែងជាបណ្តោះអាសន្នណាមួយនៃមេដឹកនាំជាន់ខ្ពស់ និងអ្នកផ្សេងទៀត ដែលមានការទទួលខុសត្រូវខ្ពស់បំផុតសំរាប់ឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងកំឡុងពេលនៃដំណើរការនេះ ។

៥៤. ហេតុដូច្នេះ ដោយសារហេតុផលទាំងអស់នេះហើយ គ្មាន "កំហុសឆ្គងដែលអាចរកឃើញ" នៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិ របស់សហចៅក្រមស៊ើបអង្កេត នៅក្នុងការសំរេចលើការឃុំខ្លួនបណ្តោះអាសន្នដែលជាវិធានការចាំបាច់ ដើម្បីធានាសណ្តាប់ធ្នាប់សាធារណៈឡើយ ។ ក្រៅពីនេះ មេធាវីការពារក្តី បានខកខាននៅក្នុងការបង្ហាញថា នឹងគ្មានគ្រោះថ្នាក់ណាមួយនឹងកើតឡើងចំពោះរបៀបរៀបរយសាធារណៈឡើយ ប្រសិនបើជនត្រូវចោទត្រូវបានដោះលែង។

### *ទទ្បីករណ៍ ទី៤*

<u>ការដាក់ការគាបសង្កត់ទៅលើសាក្សី (វិធាន ៦៣.៣.ខ.១)</u>

៥៥. សហចៅក្រមស៊ើបអង្កេត មិនបានលើកឡើងច្បាស់លាស់ទេ អំពីសេចក្តីសន្និដ្ឋានដាក់បន្ទុករបស់សហព្រះអាជអាជ្ញា ដូចបានផ្តល់នៅក្នុងថាខណ្ឌទី១១៨.គ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ

ស៊ើបសួរ និងដូចបានបរិយាយយ៉ាងល្អិតល្អន់នៅក្នុងកិច្ចពិភាក្សាដេញដោល ថាការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការចាំបាច់ ដើម្បីរារាំងកុំឲ្យជនត្រូវចោទគាបសង្កត់ទៅលើសាក្សី។ គេអាចទាញយកការខកខាននេះថា សហចៅក្រមស៊ើបអង្កេត បានខកខានក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួននៅត្រង់តែចំណុចមួយនេះគត់ ។ សហព្រះរាជអាជ្ញា សូមដាក់ជូនថា នៅក្នុងពេលអវត្តមាននៃការសំរេចណាមួយដោយសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះមានសិទ្ធិដាក់ជំនួសតាមឆន្ទានុសិទ្ធិផ្ទាល់ខ្លួន ។ ដូច្នេះសេចក្ដីសន្និដ្ឋានដាក់បន្ទុករបស់ សហព្រះរាជអាជ្ញា ទៅលើទឡ្ហីករណ៍បន្ថែម មានជាអាទិ៍ ដូចតទៅ។

៥៦. ជាប្រធាននៃមន្ទីរសន្តិសុខដ៏សំខាន់បំផុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជនត្រូវចោទបានចាត់ចែង មន្ទីរស-២១ ជាមួយនឹងខ្សែរយៈយ៉ាងសម្ងាត់ ។ ការទំនាក់ទំនងរវាង និងក្នុងចំណោមអ្នកជាប់ឃុំ និងបុគ្គលិក ត្រូវបានត្រួតត្រាយ៉ាងតឹងរឹងបំផុត។ នៅក្រោមសិទ្ធិអំណាចរបស់គាត់ អ្នកទោសជាង ១៤,០០០ នាក់ ត្រូវបានជាប់ឃុំ ធ្វើទារុណកម្ម និងសម្លាប់ចោល ដែលនៅក្នុងចំនួននេះ មានតែមួយក្ដាប់ប៉ុណ្ណោះដែលនៅរស់ ។ នៅក្រោមសិទ្ធិអំណាចរបស់គាត់ បុគ្គលិកមន្ទីរស-២១ ខ្លួនឯងផ្ទាល់ ក៏ទទួលរងនឹងរបបដ៏យង់ឃ្នងនេះដែរ ជនណាមិនបានគោរពយ៉ាងហ្មត់ចត់តាមវិធាន នឹងត្រូវចាប់ខ្លួនដោយចោទថា ក្បត់ ត្រូវទទួលទារុណកម្ម និងសម្លាប់ចោលនៅក្នុងមណ្ឌល ។ ទាំងនេះរួមបង្កើតបាននូវ "អារម្មណ៍ភ័យខ្លាចនៅគ្រប់ទីកន្លែងនៅក្នុងចំណោមសមមិត្ត" ដែលបំរើការងារជាឆ្មាំគុក[36] ។

៥៧. អ្នកនៅរស់រានមានជីវិតទាំងអស់ពី មន្ទីរស-២១ មិនថាពួកគេអតីតជាអ្នកទោស ឬ ជាបុគ្គលិកនោះទេ គឺជាសាក្សីដ៏សំខាន់បំផុតខានមិនបាន ។ អ្នកខ្លះក្នុងចំណោមពួកគេ បានផ្ដល់បទសម្ភាសន៍ជាមួយអ្នកសិក្សាស្រាវជ្រាវ និងអ្នកកាសែត ។ ក្នុងករណីខ្លះ អត្តសញ្ញាណរបស់ពួកគេត្រូវបានគេស្គាល់យ៉ាងទូលំទូលាយ ។ សាក្សីសំខាន់ៗភាគច្រើននៃពួកគាត់ ជាជនចាស់ជរា អ្នកខ្លះទៀតមានសុខភាពទន់ខ្សោយ ហើយក៏គ្មានអ្នកណាម្នាក់បានទទួលផលប្រយោជន៍

[36] សូមមើលសៀវភៅ ដោយ វេៀ ម៉េងទ្រី និង ស៊ឹម សុរិយា "ជនរងគ្រោះ និងជនល្មើស" - ការផ្ដល់កសិណនៃកម្មាភិបាលខ្មែរក្រហមវ័យក្មេង (ភ្នំពេញ: មជ្ឈមណ្ឌលឯកសារ កម្ពុជា ឆ្នាំ២០០១) ទំព័រទី ៣៥ (ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ 4.31, ERN 00079767) (សូមមើលឯកសារបន្ថែម ឈ) ។

ពីវិធានការដ៏ទូលំទូលាយណាមួយ ដើម្បីការពារសុវត្ថិភាពពួកគាត់នោះដែរ ។ គេសង្ឃឹមថា សាក្សីសំខាន់ៗភាគច្រើនលើសលុប នឹងអាចមានលទ្ធភាពនិយាយអំពីសិទ្ធិអំណាច និង ឥទ្ធិពលនៃជនត្រូវចោទ និងអាចជួយដល់សហចៅក្រមស៊ើបអង្កេតបាន ក្នុងការកំណត់អំពី ការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្រោមការស៊ើបសួរនេះ ។

៥៨. វាទំនងជានឹងត្រូវបានប្រកាសផ្សព្វផ្សាយជាសាធារណៈយ៉ាងទូលំទូលាយ ប្រសិនបើមានការ ជ្រៀតជ្រែក ការគាបសង្កត់ និងការគ្រោះថ្នាក់ចំពោះសាក្សីផ្ទាល់ភ្នែកដែលនៅសេសសល់តែ មួយចំនួនតូចបំផុតនេះ ចំពោះព្រឹត្តិការណ៍នៅ មន្ទីរស-២១ ។ នេះនឹងនាំឱ្យមានផលវិបាក យ៉ាងធ្ងន់ធ្ងរជះត្រឡប់មកវិញ ទៅលើឆន្ទៈរបស់សាក្សីដ៏សំខាន់ដទៃទៀតក្នុងការចូលរួម និងអាចធ្វើឱ្យខូចធ្ងន់ធ្ងរដល់ការស៊ើបសួរ ។ អង្គជំនុំជម្រះនៅ ICTY ករណី *ព្រះរាជអាជ្ញា ទល់នឹង Haradinaj*[37] បានថ្លែងក្នុងពេលថ្មីៗបំផុតនេះអំពី "ការចាំបាច់ក្នុងការធានា បូរណៈភាពនៃដំណើរការនីតិវិធី ដោយជៀសវាងនូវ...ហានិភ័យណាមួយដែលគូភាគីអាចនឹង គ្មានលទ្ធភាព ក្នុងការបង្ហាញភស្តុតាងចាំបាច់សំរាប់គាំទ្រទៅលើករណីនីមួយៗរបស់ខ្លួន"[38] ។ យុទ្ធសាស្ត្រនេះ ក៏សូមលើកស្នើជូន អង្គបុរេជំនុំជម្រះ ឱ្យធ្វើការពិចារណាផងដែរ ។

៥៩. ដូចបានពិភាក្សារួចមកហើយ ជនត្រូវចោទបានអះអាងថា សិទ្ធិអំណាចរបស់គាត់ត្រូវបាន កំហិត និងថា ភាពជាប្រធានរបស់គាត់នៅ មន្ទីរស-២១ គឺគ្រាន់តែជាទ្រឹស្តីប៉ុណ្ណោះ[39] ។ គេ សង្ឃឹមថា សាក្សីសំខាន់ៗនឹងនិយាយផ្ទុយពីនេះ ។ ដូច្នេះពិតណាស់ថា ជនត្រូវចោទមាន បំណងដាក់ការគាបសង្កត់ទៅលើសាក្សី ។

---

[37] *ករណី ព្រះរាជអាជ្ញា ទល់នឹង Haradinaj* សេចក្តីសំរេចចំពោះពាក្យសុំការដោះលែងបណ្តោះអាសន្ន ជំនួសមុខឱ្យ Ramush Haradinaj សំណុំរឿងលេខ IT-04-84-T អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY ចុះថ្ងៃទី២០ កក្កដា ២០០៧..

[38] *ករណី ព្រះរាជអាជ្ញា ទល់នឹង Haradinaj* សេចក្តីសំរេចចំពោះពាក្យសុំការដោះលែងបណ្តោះអាសន្ន ជំនួសមុខឱ្យ Ramush Haradinaj សំណុំរឿងលេខ IT-04-84-T អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY ចុះថ្ងៃទី២០ កក្កដា ២០០៧ កថាខណ្ឌទី ៣០..

[39] សូមមើលកថាខណ្ឌទី៣៥ ខាងលើ។

៦០. របាយការណ៍នានាបានបង្ហាញថា នៅក្នុងចំណោមសាក្សីសំខាន់ៗទាំងអស់ចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ មានការសាយភាយនៃការភ័យខ្លាចក្នុងការផ្ដល់កសិណសាក្សីនៅចំពោះមុខ អ.វ.ត.ក អាស្រ័យដោយមានការព្រួយបារម្ភខ្លាចមានការសងសឹង និងការបំភិតបំភ័យ[40] ។ នេះអាចមើលឃើញតាមសភាពការណ៍ទូទៅរបស់ប្រទេស ជាទីកន្លែងដែលវិធានការការពារសាក្សី ប្រសិនបើមានគឺតិចតួចប៉ុណ្ណោះ និងជាទីកន្លែងដែលនៅតែមានឧប្បត្តិហេតុនៃបទល្មើសដ៏សាហាវ និងលទ្ធភាពដែលអាចទទួលបាននូវអាវុធនិងជាតិផ្ទុះ នៅឡើយ[41] ។

៦១. វាទំនងដែលថា ជនត្រូវចោទបានបន្តការទាក់ទងជាមួយអតីតខ្មែរក្រហម និងអាចទទួលបានការគាំទ្រខ្លះៗនៅតាមតំបន់ជាក់លាក់មួយចំនួន ។ គាត់បានប្រាប់អ្នកកាសែត Nic Dunlop ក្នុងឆ្នាំ១៩៩៩ ថា គាត់នឹងត្រូវបាន “ការពារ” ប្រសិនបើគាត់ទៅនៅសំឡូត ដែលជាទីប្រជុំជនមួយ ដែលមានការគាំទ្រយ៉ាងខ្លាំងពីសំណាក់ពួកខ្មែរក្រហម[42] ។ ការគាំទ្រនេះ បានបង្កើន

---

[40] សូមមើលផងដែរ ឯកសាររបស់ Geerteke Jansen, *Voice from Takeo (សម្លេងពីខេត្ត តាកែវ)៖* ការសាកល្បងវាយតម្លៃអំពីការភ័យខ្លាច ទាក់ទិននឹងសាក្សីដែលអាចរកបានសំរាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ភ្នំពេញ មជ្ឈមណ្ឌលឯកសារកម្ពុជា តុលា ឆ្នាំ២០០៦) (សូមមើលឯកសារបន្ថែម ជ)។

[41] សូមមើល ក្រុមជំនួយជប៉ុន សំរាប់ការគ្រប់គ្រងអាវុធធុនតូច នៅកម្ពុជា: “កំណត់ហេតុនៃការប្រមូលអាវុធ ២០០៥ - ២០០៧” (JSAC, 2007); បង្ហាញថាមានអាវុធធុនតូច ចំនួន១៦៩៤០ដើម គ្រាប់ចំនួន៦៦៣៧៣គ្រាប់ និងជាតិផ្ទុះចំនួន ៨៧៥៤ ត្រូវបានប្រមូលនៅក្នុងខេត្តកំពង់ធំ និងបាត់ដំបង នៅចន្លោះខែ កញ្ញា ឆ្នាំ២០០៥ ដល់ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០៧ (សូមមើលឯកសារបន្ថែម ញ); Christine WILLE “តើមានអាវុធប៉ុន្មាននៅកម្ពុជា?” ការសិក្សាស្ទាបស្ទង់អាវុធធុនតូច (Geneva៖ការសិក្សាស្ទាបស្ទង់អាវុធធុនតូច ២០០៥) តាមការប៉ាន់ស្មានបង្ហាញឲ្យឃើញថា អាវុធមានចំនួនចន្លោះពី ២២០០០ និង៨៥០០០ ដើម ត្រូវបានកាន់កាប់ដោយខុសច្បាប់នៅក្នុងប្រទេសកម្ពុជា (សូមមើលឯកសារបន្ថែម ដ); “សេចក្ដីសង្ខេបនៃសេចក្ដីថ្លែងការណ៍របស់លោក ចោ សារ៉ន ចៅក្រមកម្ពុជា” នៅក្នុងរបាយការណ៍នៃ សិក្ខាសាលាថ្នាក់ជាតិ ស្ដីពីការលើកកំពស់ការយល់ដឹងអំពីច្បាប់គ្រប់គ្រងអាវុធ ថ្ងៃទី១៦ ដល់១៨ ខែកក្កដា ឆ្នាំ២០០៦ ទំព័រ១៥ ដល់១៦ (ក្រុមការងារដើម្បីកាត់បន្ថយអាវុធ ២០០៦) ដោយពិភាក្សាអំពីបញ្ហានៃការបង្កហេតុដោយអាវុធធុនតូចនៅកម្ពុជា (សូមមើលឯកសារបន្ថែម ឋ)។ សូមមើលផងដែរ “ការដុតបំផ្លាញអាវុធជួយបណ្ដេញចេញកេរ្ដិ៍ដំណែលស្លាប់រស់របស់ខ្មែរក្រហមនៃកម្ពុជា” *Associated Press* ចុះថ្ងៃទី ៣០ ខែមិនា ឆ្នាំ២០០៥ ដែលពិពណ៌នាអំពី ការដុចបំផ្លាញកាំភ្លើងដៃ កាំភ្លើងបាញ់គ្រាប់រ៉ុកកែត និងគ្រាប់រំសេវជាង ៣៥០០ ដើម ដែលជាផ្នែកមួយនៃការព្យាយាមកំទេចចោលអាវុធយុទ្ធភ័ណ្ឌដែលនៅរាយប៉ាយពាសពេញបន្សល់ទុកនៅក្នុងពេលមានជម្លោះនៅប្រទេសកម្ពុជា (សូមមើលឯកសារបន្ថែម ឌ)។

[42] សូមមើលសៀវភៅរបស់ Nic Dunlop, ដែលមានចំណងជើងថា *The Lost executioner* (អ្នកពិឃាតដែលបាត់ខ្លួន)០: *រឿងរបស់ខ្មែរក្រហម* (Bloomshury: 2005) ទំព័រទី២៥២ (សូមមើល ឯកសារបន្ថែម ខ)។

ដល់ហានិភ័យ ដែលថា គាត់អាចរកអ្នកផ្សេងឱ្យជួយគាត់ ដើម្បីដាក់ការគាបសង្កត់ទៅលើសាក្សី ។

៦២. នៅក្នុងកំឡុងពេលនៃកិច្ចពិភាក្សាដេញដោល មេធាវីការពារក្តីបានដាក់ជូនថា ជនត្រូវចោទមិនបាន ស្គាល់ឈ្មោះសាក្សីសំខាន់ៗណាម្នាក់ឡើយ ។ ប៉ុន្តែ នៅក្នុងពេលធ្វើសម្ភាសន៍នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គាត់បានស្ម័គ្រចិត្តផ្តល់ឈ្មោះអ្នកជាប់ឃុំនៅមន្ទីស-២១ ដែលអាចជាសាក្សីនៅចំពោះមុខតុលាការនេះ ។ ការអះអាងរបស់គាត់ដែលថា គាត់មិនស្គាល់ឈ្មោះសាក្សីណាម្នាក់ គឺជាការខុសទេ ។ ទោះនៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ គាត់អាចបានដឹងនូវសំណុំរឿងដ៏ពេញលេញមួយរួចហើយ រួមទាំងឈ្មោះសាក្សីសំខាន់ៗដែលអាចចូលមកផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនគាត់ទៀតផង ។ ប្រដាប់ទៅដោយការដឹងរបស់គាត់នេះហើយ គាត់មានសក្តានុពល ដើម្បីដាក់ការគាបសង្កត់ទៅលើពួកគេ ។

៦៣. ហេតុដូចនេះ អង្គបុរេជំនុំជម្រះ មានសិទ្ធិស្វែងរកទឡ្ហីករណ៍ដែលមាន ដើម្បីធ្វើយុត្តិកម្មចំពោះសេចក្តីសន្និដ្ឋានដែលថា ការឃុំខ្លួនជាបណ្តោះអាសន្ន គឺជាវិធានការមួយដ៏ចាំបាច់ ដើម្បីរារាំងកុំឱ្យជនត្រូវចោទ គាបសង្កត់ទៅលើសាក្សី និងជនរងគ្រោះ។

## ការផ្អែកទៅលើសំណុំរឿងនិមួយៗនៅក្នុងតុលាការ ICTY ដែលគេបានអនុញ្ញាតឱ្យធ្វើការដោះលែង

៦៤. មេធាវីការពារក្តី បានអះអាងថាមានករណីយុត្តិសាស្ត្រជាច្រើន នៅចំពោះមុខតុលាការផ្សេងៗទៀត ស្តីពីការដោះលែងជនដែលគេសង្ស័យថាបានប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ដែលត្រូវបានដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ។ ករណីរឿងទាំងអស់នេះអាចនឹងញែកដាច់ពីគ្នាយ៉ាងច្បាស់បាន ដោយផ្អែកលើទឡ្ហីករណ៍ខាងអង្គហេតុ[43] ។ *ជាទូទៅ*

[43] ករណីរឿងក្តី ករណីរឿងក្តីរបស់ Haradinaj, Ademi and Adzhihasanovic ដែលហៅផងដែរថា"ជនចាប់ចោទដែលប្រែក្រឡះ"(flip-side accuased) ដែលសុទ្ធតែជាមបញ្ហាការនៃកងទ័ពការពារដែលបទល្មើសរបស់ពួកគេមានកំរិតស្រាលជាងរបស់ជនជាប់ចោទ ជនជាតិស៊ែប: ករណីរឿងក្តីរបស់រដ្ឋអាជ្ញាទល់នឹង *Haradinaj*-សេចក្តីសំរេចលើញត្តិសុំដោះលែងឱ្យនៅក្រៅឃុំចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងការឃុំខ្លួនបណ្តោះអាសន្ន លើឈ្មោះ ឌុច

ការអនុញ្ញាតយល់ព្រម ឬមិនយល់ព្រមដោះលែងឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ចំពោះករណីដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិដ៏ធ្ងន់ធ្ងរ គឺមានតម្លៃដែលមានកំរិតកំណត់ ។ វាគឺជាបទដ្ឋានអន្តរជាតិដែលត្រូវបានគេទទួលស្គាល់ថា សេចក្តីសំរេចស្តីពីការដោះលែងឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ចាំបាច់ត្រូវតែលើកឡើងអំពីកាលៈទេសៈជាក់លាក់របស់ករណីនីមួយៗនោះ[44] ។ អង្គបុរេជំនុំជម្រះត្រូវបានអញ្ជើញឱ្យធ្វើសេចក្តីសន្និដ្ឋានថា សេចក្តីសំអាងរបស់មេធាវីការពារក្តីលើចំណុចនេះ គឺអាចជួយបានតិចតួចបំផុត ។

## មិនមែនជាកំហុសទេក្នុងការបដិសេធន៍ មិនដាក់លក្ខខណ្ឌតម្រូវឱ្យដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

៦៥. សហចៅក្រមស៊ើបអង្កេត បានសម្រេចថា គ្មានដីកាសំរេចឱ្យឋិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយ ដែលមានការប្រុងប្រយ័ត្នឱ្យបានគ្រប់គ្រាន់ល្មម ដើម្បីបំពេញ

---

បណ្ដោះអាសន្ន របស់ Ramush Haradinaj,សំណុំរឿងលេខ IT-04-84-PT,របសអង្គជំនំជម្រះសាលាដំបូងនៃតុកាការព្រហ្មទណ្ឌសំរាប់អតីត ប្រទេសយូហ្គោស្លាវី (ICTY) ចុះថ្ងៃទី៦ មិថុនា ២០០៥ ។ ករណីរឿងក្តីរបស់រដ្ឋអាជ្ញាទល់នឹង *Ademi*-សេចក្តីសំរេចលើញត្តិ សុំដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នន សំណុំរឿងលេខ IT-01-46-PT,របស់ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌសំរាប់អតីតប្រទេសយូហ្គោស្លាវី(ICTY) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ ។ ករណីរឿងក្តីរបស់រដ្ឋអាជ្ញាទល់នឹង *Hadzihasanovic*-សេចក្តីសំរេចអនុញ្ញាតឲ្យដោះលែង Enver Hadzihasanovic ឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ,សំណុំរឿង លេខ IT-01-47-PT,របស់អង្គជំនុំជម្រះសាលាដំបូងនៃ ICTY ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២។ ជនជាប់ចោទទាំងនេះត្រូវបានចោទប្រកាន់លើឃាដករម្នាក់ៗជាលក្ខណៈបុគ្គលពីបទឧក្រិដ្ឋកម្មសង្គ្រាម/ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ តាមពិតសាលក្រមចុង ក្រោយបំផុតរបស់អង្គជំនុំជម្រះសាលាដំបូងពីក្នុងករណីរឿងក្តី រដ្ឋអាជ្ញាទល់និង *Haradinaj*ដែលបានបដិសេធមិនព្រមដោះលែង ជនជាប់ជោទឱ្យនៅក្រៅឃុំនៅក្នុងពេកវិស្សមកាលនារដូវក្តៅ ទោះបីជាមានមូលហេតុខ្លាំងៗផ្សេងពីនេះដែលបញ្ជាក់ពីភាពត្រឹមត្រូវក៏ដោយ គឺដោយផ្អែកលើមូលដ្ឋានការអន្តរាគមន៍របស់សាក្សី ។ ករណីរឿងក្តីរបស់រដ្ឋអាជ្ញាទល់នឹង *Haradinaj*-សេចក្តីសំរេចលើញត្តិសុំដោះលែងឱ្យនៅក្រៅឃុំ បណ្ដោះអាសន្នតាងនាមឱ្យ Ramush Haradinaj,សំណុំរឿងលេខ IT-04-84-T,របស់អង្គជំនំជម្រះសាលាដំបូងនៃ ICTY ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៥ ។

[44] *ករណីរឿងរដ្ឋអាជ្ញាទល់នឹង Ljube Boskoski and Johan Tarculovski* សេចក្តីសម្រេចលើបណ្ដឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំរបស់ Johan Tarculovski ស្តីពីសំណើដោះលែងជាបណ្ដោះអាសន្ន, របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ ICTY សំណុំរឿងលេខ IT-04-82-AR65.04 , ថ្ងៃទី២៧ កក្កដា ឆ្នាំ២០០៧, កថាខណ្ឌទី៦។

00154589



តាមសេចក្តីត្រូវការក្នុងការធានាអំពីវត្តមានរបស់ជនត្រូវចោទ ការការពារសុវត្ថិភាពផ្ទាល់របស់គាត់ និង ការរក្សាសណ្តាប់ធ្នាប់សាធារណៈនោះទេ[45]។

៦៦. សហព្រះរាជអាជ្ញាគាំទ្រចំពោះការលើកហេតុផលនេះ ។ ទម្រង់តែមួយគត់នៃការត្រួតមើលរបស់តុលាការដែលបានចែងនៅក្នុងវិធានផ្ទៃក្នុងនោះគឺ ដីកាសំរេចឱ្យឋិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការក្រោមវិធាន៦៥។ សហចៅក្រមស៊ើបអង្កេត ផ្អែកតាមសំណើរបស់គូភាគីឬមួយក៏តាមញត្តិរបស់ពួកគេ ត្រូវបានផ្តល់អំណាចក្នុងការដោះលែងជនត្រូវចោទ ហើយអាចបង្គាប់ឱ្យបង់ប្រាក់ធានា និង/ឬ ដាក់ជាលក្ខខណ្ឌផ្សេងៗតាមការចាំបាច់ដើម្បីធានាឱ្យប្រាកដអំពីវត្តមាន របស់ជននោះនៅក្នុងពេលដំណើរការនិតិវិធី និងធានាការការពារដល់ជនដទៃទៀត។ លក្ខខណ្ឌដូចនេះ មិនបានផ្តល់និយមន័យលើសពីនេះទេ ។

៦៧. ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីរបស់កម្ពុជាទើបតែដាក់បញ្ចូលក្នុងពេលថ្មីៗនេះនូវទស្សនទានអំពីសេចក្តីសំរេចឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ[46] ។ គ្មានយុត្តិសាស្ត្រ គ្មានបទពិសោធន៍អនុវត្ត ឬគ្មានការបង្ហាញសក្ខីកម្មអំពីសមត្ថភាពក្នុងការផ្តល់ការការពារ ឬពីយន្តការអនុវត្តសម្រាប់ ជនសង្ស័យទាំងឡាយដែលអាចនឹងត្រូវបានដោះ លែងដោយការបង់ប្រាក់ធានានោះទេ ជាពិសេសជនសង្ស័យទាំងឡាយដែលគេមានការដឹងឮគ្រប់ៗគ្នាថាជាជនត្រូវចោទ។ នៅគ្រប់ករណីទាំងអស់ មេធាវីមិនបានផ្តល់នូវអង្គហេតុដើម្បីគាំទ្រថា តើសំណើសុំឱ្យមានការត្រួតពិនិត្យរបស់តុលាការ ណាមួយចំពោះជនត្រូវចោទ ដែលត្រូវបានបើកឱ្យមានសេរីភាព និងត្រូវប្រតិបត្តិការបែបដូចម្តេច តើគេនឹងត្រូវរស់នៅទីណា និងតើត្រូវដាក់គេបែបដូចម្តេចដើម្បីឱ្យបាននៅដាច់ដោយឡែកពីសាក្សី ជនរងគ្រោះ ឬជនសមគំនិតនានានោះ ។

## សេចក្តីសន្និដ្ឋាន

៦៨. បណ្តឹងឧទ្ធរណ៍របស់មេធាវីបានខកខានមិនបានចង្អុលបង្ហាញថា សេចក្តីសម្រេចរបស់

---

[45] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣១ កក្កដា ២០០៧ កថាខណ្ឌទី ២៣។

[46] មាត្រា២២៣-២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧។

សហចៅក្រមស៊ើបអង្កេតដែលត្រូវបានតវ៉ាពីការដែល ធ្វើឲ្យរងការឈឺចាប់មកពីការភ័ន្តច្រឡំណាមួយដែលអាចនឹងដឹងបាននោះទេ ។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក៏មិនបាន ផ្អែកលើការបកស្រាយច្បាប់នៃច្បាប់គ្រប់គ្រងការឃុំខ្លួនបណ្តោះអាសន្នដែលមិនត្រឹមត្រូវដែរ។ ផ្ទុយទៅវិញវិធាន៦៣នៃវិធានផ្ទៃក្នុងត្រូវបានអនុវត្តយ៉ាងម៉ត់ចត់។ បណ្តឹងឧទ្ធរណ៍នោះមិនបានចង្អុលបង្ហាញថា សេចក្តីសម្រេចត្រូវបានផ្អែកលើសេចក្តីសន្និដ្ឋានដែលជាគំរូមិនត្រឹមត្រូវ ឬត្រូវបានឈានឡើងដល់ការរំលោភចំពោះ សេចក្តីសម្រេចចិត្តនោះទេ។ សហចៅក្រមស៊ើបង្កេតបានឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានដែលពួកគេបានធ្វើដោយមានការបញ្ជាក់អំពីភាពត្រឹមត្រូវយ៉ាងពេញលេញ ។

៦៩. ដោយពិនិត្យពិចារណាអំពីមូលហេតុផ្សេងៗក្នុងការឃុំខ្លួនបណ្តោះអាសន្នដូចបានលើកយកមកសំអាងខាងលើនេះ ហេតុដូចនេះគឺគ្មាន"ការភ័ន្តច្រឡំដែលអាចដឹងបាននោះទេ" នៅក្នុងការអនុវត្តន៍ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតក្នុងការរកឱ្យឃើញថាមិនមានការដាក់លក្ខខណ្ឌផ្សេងៗក្នុងការបង់ប្រាក់ធានាដែលអាចនឹងធានាយ៉ាងគ្រប់គ្រាន់អំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងពេលដំណើរការនីតិវិធីផ្សេងៗផង និងធានាអំពីការការពារដល់ជនដទៃៗទៀតផង ។

## សំណើ ២

## គ្មានការភ័ន្តច្រឡំនៅក្នុងការមិនបានយល់ព្រមឱ្យដោះលែងជនត្រូវចោទជាបន្ទាន់

៧០. មេធាវីដាក់ជូនថា បើសិនជាមូលហេតុផ្សេងៗនៃការឃុំខ្លួនត្រូវបានបំពេញហើយនោះ ក៏មានការរំលោភបំពានដល់សិទ្ធិនានាជាមូលដ្ឋានរបស់ជនត្រូវចោទ ដែលកំពុងត្រូវបានឃុំ ខ្លួនដែរ ដោយដីកាបង្គាប់របស់តុលាការយោធាលើសពី៨ឆ្នាំនោះថា គឺជារយៈពេល អប្បបរមាមួយដែលជនត្រូវចោទរូបនោះគួរតែត្រូវបានដោះលែង ជាបន្ទាន់ពីការឃុំខ្លួនបណ្តោះអាសន្ន ។

៧១. សហចៅប្រស៊ើបអង្កេតបានបដិសេធលើសំណើដាក់ជូនរបស់មេធាវី ដោយសារមូលហេតុពីរយ៉ាង។ ទី១ គឺដោយចៅក្រមលើកហេតុផលថា អ.វ.ត.ក មិនមានយុត្តាធិការដើម្បី

00154591



ធ្វើការពិនិត្យសំរេចអំពីនីត្យានុកូលភាពនៃការឃុំខ្លួនពីមុនមករបស់ជនត្រូវចោទទេ[47]។ ការរំលោភសិទ្ធិរបស់ជនត្រូវចោទដែលអាចមានពីមុនមកនោះ គឺមិនមែនជាកំហុសរបស់ អ.វ.ត.ក ទេ។ ទី២ ចៅក្រមប្រកាន់យកសំអាងថា ការរំលោភបំពាននោះក្នុងករណីណាក៏ដោយមិនទាន់ឈានដល់កំរិតធ្ងន់ធ្ងរដែលតម្រូវឱ្យតុលាការត្រូវធ្វើអន្តរាគមន៍នោះទេ។ អាស្រ័យហេតុនេះ ដំណោះស្រាយណាមួយក៏ដោយចំពោះការរំលោភ បំពាននោះមិនមានជាបញ្ហាចោទនៅក្នុងដំណាក់កាលស៊ើបសួរទេ[48]។

## *ផ្នែកទី I*

## ការបំពាននេះ គឺមិនមែនជាកំហុសរបស់ អ.វ.ត.ក ទេ

៧២. សហចៅក្រមស៊ើបអង្កេត បានប្រកាន់យកសំអាងថា ពួកគេមិនមានយុត្តាធិការដើម្បីកំណត់អំពីនីត្យានុកូលភាពនៃការឃុំខ្លួនពីមុនមកនៃជនត្រូវចោទនោះទេដោយផ្អែកលើមូលហេតុ[49]៖

(i) អវតក ទើបតែនឹងបានដំណើរការកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧មកតែប៉ុណ្ណោះ ដែលជាកាលបរិច្ឆេទដែលវិធានផ្ទៃក្នុងចូលជាធរមាន។ ហើយ

(ii) មុនការផ្តួចផ្តើមគំនិតក្នុងការធ្វើការស៊ើបសួរបច្ចុប្បន្ននេះ សហចៅក្រមស៊ើបអង្កេត ដែលជាសមត្ថកិច្ចតែមួយគត់ ដែលត្រូវបានផ្តល់អំណាចក្នុងការសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន មិនមានមធ្យោបាយដើម្បីធ្វើអន្តរាគមន៍ទេ ។

៧៣. ជនត្រូវចោទត្រូវបានឃុំខ្លួនចាប់តាំពីឆ្នាំ១៩៩៩មក ដោយតុលាការយោធា ។

៧៤. មេធាវីបានដាក់ជូនសំណើថា ដោយចេញដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវចោទជាបណ្តោះអាសន្ន រយៈពេលចំនួន១ឆ្នាំ“បន្ថែម”ទៀតនោះ គឺសហចៅក្រមស៊ើបអង្កេត បាន“ផ្តល់សុពលភាព” ដល់ដីកាឃុំខ្លួនបណ្តោះអាសន្នរបស់តុលាការយោធា ។ គឺហាក់ដូចជាថា មេធាវីបានលើក

[47] យោងកថាខណ្ឌទី ២០។

[48] កថាខណ្ឌទី ២១។

[49] កថាខណ្ឌទី ២០។

សំអាងថា ដំណើរការនិតិវិធីរបស់ អវតក គឺជាការបន្តដំណើរការនៃនីតិវិធីតពីតុលាការយោធាមក ហើយថាដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត គឺដាក់បញ្ចូលគ្នាជាមួយការ ឃុំខ្លួនពីមុនមកដែលអង្គបុរេជំនុំជម្រះត្រូវ តែផ្ដល់នូវដំណោះស្រាយមួយ ។

៧៥. សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា ភ្លាមៗបន្ទាប់ពីសហចៅក្រមស៊ើបអង្កេតបានទទួលនូវសំណុំរឿងរបស់ជនត្រូវចោទពួកគេបានចាប់ផ្ដើមដំណើរការរឿងក្ដីនេះនៅក្នុងរយៈពេល ១២ថ្ងៃ[50] ។

៧៦. សហព្រះរាជអាជ្ញាស្នើដាក់ជូនថា ជាជាងការ"ផ្ដល់សុពលភាព"ចំពោះដីកាបង្គាប់ឱ្យឃុំខ្លួនពីមុនមកដោយតុលាការយោធា ដីការបស់សហចៅក្រមស៊ើបអង្កេតគឺជាការធ្វើសេចក្ដីសម្រេចមួយដោយឯករាជ្យ ដោយអនុវត្តយុត្តាធិការតែមួយគត់របស់ខ្លួន នៅក្នុងថា ៖

(i) អ.វ.ត.ក គឺជាស្ថាប័នតុលាការឯករាជ្យមួយដាច់ដោយឡែកពីតុលាការយោធា ។

(ii) អ.វ.ត.ក មិនដែលបានដំណើរការការងារដោយមានការព្រមព្រៀងគ្នាជាមួយ ឬក៏មិនបានអនុម័តយកតាមសកម្មភាពរបស់តុលាការយោធាទាល់តែសោះ ។

## (i) អំពីឯករាជ្យភាពរបស់ អ.វ.ត.ក

៧៧. អ.វ.ត.ក និងតុលាការយោធាក្នុងស្រុកគឺគ្មានការតភ្ជាប់ទំនាក់ទំនងអំពីឯករាជ្យភាព និងអំពីផ្លូវច្បាប់ឬ មុខងារអ្វីជាមួយគ្នានោះទេ ។ អ.វ.ត.ក មិនត្រូវបានដាក់ឱ្យឋិតនៅក្រោមការត្រួតពិនិត្យ ឬការពិនិត្យសារឡើងវិញដោយអាជ្ញាធរជាតិណាមួយនោះទេ ។ ហើយ អ.វ.ត.ក ក៏មិន អាចត្រូវជាប់កាតព្វកិច្ចអនុវត្តតាមឬ ចាប់បង្ខំតុលាការផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជាបានទេ ។ ផ្ទុយទៅវិញ អ.វ.ត.ក មានប្រភេទលក្ខណៈផ្សេងដាច់ដោយឡែកដែលធ្វើឱ្យតុលាការនេះក្លាយទៅជា "តុលាការអន្តរជាតូបនីយកម្មពិសេសមួយ"[51] ៖

---

[50]កឋាខណ្ឌទី២០-គឺជាការផុតរយៈពេលកំណត់ចន្លោះពេលរវាងការដាក់ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនិងដីកាឲ្យនាំខ្លួន។

[51] ក្នុងពាក្យពេចន៍របស់សហចៅក្រមស៊ើបអង្កេតក្នុងដីកាបង្គាប់អោយឃុំខ្លួនជាបណ្ដោះអាសន្ន កឋាខណ្ឌទី២០។

(i) គឺតុលាការនេះត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញាអន្តរជាតិ[52] ។

(ii) តុលាការនេះត្រូវបានបង្កើតឡើងដើម្បីដោះស្រាយចំពោះការរំលោភបំពានផ្សេងៗ យ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិនិងច្បាប់អន្តរជាតិ ដែលជា"ការព្រួយបារម្ភដ៏សំខាន់ជាអាយុជីវិតដល់សហគមន៍អន្តរជាតិ"[53] អាស្រ័យហេតុនេះវាគឺជា "ផ្នែកនៃយន្តការយុត្តិធម៌របស់អន្តរជាតិ[54] សំរាប់ការប្រយុទ្ធប្រឆាំងនឹងអំពើឧក្រិដ្ឋកម្មផ្សេងៗ ។

(iii) យុត្តាធិការរបស់តុលាការនេះគឺខុសគ្នាខ្លាំងណាស់ទៅនឹងយុត្តាធិការនៃតុលាការនានារបស់ប្រទេសកម្ពុជាដែលមានការកម្រិតកំណត់ព្រំដែនទាំងអំពីបទល្មើស[55] អំពីពេលវេលា[56] និងអំពីបុគ្គល[57] ។

(iv) គ្មានបណ្តឹងឧទ្ធរណ៍ណាដែលប្តឹងអំពីតុលាការដទៃៗទៀតក្នុងប្រទេសកម្ពុជាត្រូវឱ្យ អវតក ជាអ្នកវិនិច្ឆ័យនោះទេ ។

(v) តុលាការនេះមានអាយុកាលដែលមានការកម្រិតកំណត់ដែលត្រូវរំលាយក្រោយពីធ្វើសេចក្តីសន្និដ្ឋានស្ថាពរនៅក្នុងដំណើរការនៃនីតិវិធីរួច[58]។

---

[52] កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអសប-ឯកសារតុលាការ។

[53] សូមអានកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអសប-ឯកសារតុលាការ។សូមអានផងដែរសេចក្តីសំរេចចិត្តរបស់មហាសន្និបាត អសប: ស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ 52/135, ចុះថ្ងៃទី២៧ កុម្ភៈ ឆ្នាំ១៩៩៨, A/RES/52/135; ការកាត់ទោសខ្មែរក្រហម សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ 57/228A, ចុះថ្ងៃទី២៧ កុម្ភៈ ឆ្នាំ២០០៣ ។ ការកាត់ទោសខ្មែរក្រហម សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ 57/228B, ចុះថ្ងៃទី២២ ឧសភា ២០០៣ ។ A/RES/57/228B ។

[54] ករណីរឿងក្តីរបស់ *រដ្ឋអាជ្ញាទល់នឹង* Ghankay Taylor, ស្តីពីអភ័យឯកសិទ្ធរួចផុតពីយុត្តាធិការ, សំណុំរឿងលេខ SCSL -2003-01-1 របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ SCSL ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ កថាខណ្ឌទី៣៨ ។

[55] កំរិតត្រឹមតែការចោទប្រកាន់លើបទឧក្រិដ្ឋជាក់លាក់ក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងសាសនា) អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌និង ឧក្រិដ្ឋកម្មប្រឆាំងនិងបុគ្គលដែលត្រូវបានទទួលការការពារជាអន្តរជាតិ(សូមអានមាត្រា ៣-៨ នៃច្បាប់ស្តីពីការបង្កើត អវតក)។

[56] កំរិតត្រឹមតែបទឧក្រិដ្ឋដែលបានប្រព្រឹត្តចន្លោះពេលពីថ្ងៃទី១៧មករាឆ្នាំ១៩៧៥និងថ្ងៃទី៦មករាឆ្នាំ១៩៧៩(មាត្រា២ច្បាប់ស្តីពីការបង្កើត អវតក)។

[57] កំរិតត្រឹមតែមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមនិងអ្នកទទួលដទៃទៀតដែលទទួលខុសត្រូវខ្ពស់បំផុត (មាត្រា២ច្បាប់ស្តីពីការបង្កើត អវតក)។

(vi) តុលាការនេះមាន ចរិតលក្ខណៈរចនាសម្ព័ន្ធតែមួយគត់ ដែលមិនស្របជាមួយនឹងតុលាការក្នុងស្រុក៖

(ក) គឺមានចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិស្វយ័ត ដែលឯករាជ្យដាច់ដោយឡែកពីឋានានុក្រមតុលាការជាតិ ។

(ខ) មានអង្គបុរេជំនុំជម្រះមួយ ដែលជាយន្តការសម្រាប់ដោះស្រាយវិវាទ ។

(គ) មានប្រព័ន្ធបោះឆ្នោតមួយដែលយកតាមសម្លេងភាគច្រើនលើសលប់ ។

(ឃ) មន្ត្រីតុលាការអន្តរជាតិជាន់ខ្ពស់នានាត្រូវបានផ្តល់នូវ "បុព្វសិទ្ធនិងអភ័យឯកសិទ្ធិ" ការលើកលែង និងគ្រឿងប្រើប្រាស់មធ្យាបាយផ្សេងៗដែលត្រូវបានអនុញ្ញាត្តិយល់ព្រមដល់ភ្នាក់ងារខាងការទូតនានា អនុលោមតាមអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦៦ ស្តីពីទំនាក់ ទំនងការទូត"[59] ។

៧៨. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូន(SCSL)នៅក្នុងករណីរឿងក្តីរបស់រដ្ឋអាជ្ញាទល់នឹង Charles Taylor បានរកឃើញនូវលក្ខណៈពិសេសមួយចំនួនទាក់ទងនឹងការពិនិត្យពិចារណាថាតុលាការពិសេសនៃប្រទេសសៀរ៉ាលេអូនគឺជា តុលាការអន្តរជាតិមួយ[60]។ ជាពិសេស ការដែលអាចបញ្ចុះបញ្ចូលបាននោះគឺអំពីប្រការដែលថាតុលាការពិសេសសំរាប់ប្រទេសសៀរ៉ាលេអូនត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញាថាការបង្កើតតុលាការនេះ "គឺជាការសម្តែងមួយនូវឆន្ទៈរបស់សហគមន៍អន្តរជាតិ"[61] ហើយថា

---

[58] កំរិតត្រឹមតែមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមនិងអ្នកទទួលដទៃទៀតដែលទទួលខុសត្រូវខ្ពស់បំផុត (មាត្រា២ច្បាប់ស្តីពីការបង្កើត អវតក)។

[59] មាត្រា៤១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[60] ករណីរឿងក្តី រដ្ឋអាជ្ញាទល់និង Charles Ghankay Taylor, ស្តីពីអភ័យឯកសិទ្ធរួចផុតពីយុត្តាធិការ, សំណុំរឿងលេខ SCSL - 2003-01-I, របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសំរាប់ប្រទេសសៀរ៉ាឡេអូន ចុះថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ២០០៤, កថាខណ្ឌទី ៤១-២។

[61] ករណីរឿងក្តី រដ្ឋអាជ្ញាទល់និង Charles Ghankay Taylor, ស្តីពីអភ័យឯកសិទ្ធរួចផុតពីយុត្តាធិការ, សំណុំរឿងលេខ SCSL - 2003-01-I, របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសំរាប់ប្រទេសសៀរ៉ាឡេអូន ចុះថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ២០០៤, កថាខណ្ឌទី ៣៨។

00154595



តុលាការនេះ "គឺជាផ្នែកនៃយន្តការយុត្តិធម៌របស់អន្តរជាតិ"[62] ។ ហើយនឹងថា យុត្តាធិការរបស់តុលាការនេះគឺសំរាប់ជំនុំជម្រះលើបទឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗដែលធ្ងន់ធ្ងរជាទីបំផុត ដែលមានភាពស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងតុលាការ ICTY, ICTR, និង ICC[63] ។

(ii) គ្មានសកម្មភាពព្រមព្រៀងរួមគ្នាធ្វើឡើងរវាង អ.វ.ត.ក និងតុលាការយោធាទេ

៧៩. អ.វ.ត.ក មិនដែលបានធ្វើសកម្មភាពដោយការព្រមព្រៀងរួមគ្នាធ្វើជាមួយតុលាការយោធាទាល់តែសោះ ប្រការដែលតុលាការយោធាបានយកច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មកប្រើក្នុងការចេញដីកាបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទនោះ គឺមិនមានផលវិបាកអ្វីទេ ។ ដើម្បីធ្វើការវាយតម្លៃអំពីការទទួលខុសត្រូវរបស់ អ.វ.ត.ក ចំពោះសកម្មភាពរបស់តុលាការយោធានោះ ចំណុចផ្តោត ត្រូវតែធ្វើទៅលើអំពើប្រព្រឹត្តដោយផ្ទាល់របស់ អ.វ.ត.ក ។

៨០. លុះត្រាតែគេអាចនិយាយបានថា តុលាការអន្តរជាតូបនីយកម្មមួយបានធ្វើសកម្មភាព "ដោយមានការព្រមព្រៀងរួមគ្នាធ្វើ" ជាមួយអាជ្ញាធរជាតិតែប៉ុណ្ណោះ នោះទើបការទទួលខុសត្រូវចំពោះអំពើរបស់អាជ្ញាធរជាតិទាំងនោះអាចនឹងត្រូវដាក់ទៅលើតុលាការនោះបាន[64]។

---

[62]ករណីរឿងក្តី រដ្ឋអាជ្ញាទល់និង Charles Ghankay Taylor, ស្តីពីអភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការ, សំណុំរឿងលេខ SCSL - 2003-01-I, របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសំរាប់ប្រទេសសៀរ៉ាឡេអូន ចុះថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ២០០៤, កថាខណ្ឌទី ៣៨។

[63] ករណីរឿងក្តី រដ្ឋអាជ្ញាទល់និង Charles Ghankay Taylor, ស្តីពីអភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការ, សំណុំរឿងលេខ SCSL - 2003-01-1, របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសំរាប់ប្រទេសសេរ៉ាឡេអូន ចុះថ្ងៃទី៣១ ឧសភា ២០០៤, កថាខណ្ឌទី ៤១(គ)។

[64] *សភាពការណ៍នៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោនៅក្នុងករណីរឿងក្តី រដ្ឋអាជ្ញាទល់នឹង Thomas Lubanga Dyilo,* សេចក្តីសំរេចលើការតវ៉ារបស់មេធាវីអំពីយុត្តាធិការរបស់តុលាការអនុលោមតាមមាត្រា ១៩(ក)នៃលក្ខន្តិកៈ- សំណុំរឿងលេខ01/04-01/06, របស់អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦, ទំព័រទី១០ ដោយការប្រចាច់បញ្ចូលគ្នាជាមួយករណីរឿងរបស់ រដ្ឋអាជ្ញាទល់នឹង *Dragan Nikolic, សេចក្តីសំរេចលើបណ្តឹង ឧទ្ធរណ៍ស្តីពីបញ្ហាបន្ទាន់បន្តិ ពីនីត្យានុកូលភាពនៃការចាប់ខ្លួន- របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ* ICTY៖-សំណុំរឿងលេខ IT-94-2-AR73, *ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៣ កថាខណ្ឌទី ៣០។ និងក្នុងករណីរឿងក្តីរបស់ រដ្ឋអាជ្ញាទល់នឹង Jean Bosco* ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងការឃុំខ្លួនបណ្តោះអាសន្ន លើឈ្មោះ ឌុច

00154596



លើសពីនេះ ការគ្រាន់តែដឹងពីសំណាក់អាជ្ញាធរខាងតុលាការអន្តរជាតិអំពីមានការស៊ើបអង្កេត ឬអំពីមានសកម្មភាពផ្សេងៗដែលអាជ្ញាធរជាតិបានអនុវត្តតែប៉ុណ្ណោះ គឺមិនអាចយក[65] ធ្វើជាភស្តុតាងថា អាជ្ញាធរអន្តរជាតិទាំងនោះបានចូលរួមនៅក្នុងការស៊ើបអង្កេតទាំងនោះ ឬមួយថាតើគេបានអនុវត្តតាមរបៀបដូចម្តេចនោះទេ ។

៨១. ក្នុងការបើកធ្វើការស៊ើបសួរប្រឆាំងនឹងជនត្រូវចោទ សហចៅក្រមស៊ើបអង្កេត នៃ អ.វ.ត.ក បានចាប់ផ្តើមដំណើរការនីតិវិធីប្រឆាំងនឹងជននេះ ដាច់ដោយឡែកពីគ្នាទាំងស្រុង ខុសពីអ្វីៗដែលកំពុងតែបន្តធ្វើនៅក្នុងតុលាការយោធា ។ គឺគ្មាននិរន្តរភាពការងារតុលាការទេ ទាំងអង្គហេតុ ឬ ទាំងអង្គច្បាប់ ដូចជារវាង ដំណើរការនីតិវិធីនៅចំពោះមុខតុលាការយោធា និង នៅចំពោះមុខ អ.វ.ត.ក៖

(i) អ.វ.ត.ក មិនដែលបានស្នើសុំឱ្យតុលាការយោធាធ្វើការឃុំខ្លួនជនត្រូវចោទទាល់តែសោះ ។

(ii) សហព្រះរាជអាជ្ញានៃ អ.វ.ត.ក បានបើកធ្វើការស៊ើបអង្កេតរបស់ខ្លួនដោយខ្លួនឯង ជាជាងការធ្វើបន្តពីការស៊ើបអង្កេតរបស់ តុលាការយោធា ។

(iii) ជនត្រូវចោទបានមកឋិតនៅចំពោះមុខ អ.វ.ត.ក គឺមិនមែនដោយសារការផ្ទេរយុត្តាធិការពីតុលាការយោធាមកនោះទេ ក៏ប៉ុន្តែដោយសារដីកាឃាត់ខ្លួន ។ នេះគឺត្រូវបានចេញដោយឯករាជ្យដាច់ដោយឡែក ដោយសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក នៅក្រោមសមត្ថកិច្ចរបស់ខ្លួនផ្ទាល់ ។

(iv) សំណុំរឿងពេញលេញរបស់តុលាការយោធាមិនដែលត្រូវបានដាក់ជូនចំពោះមុខ សហចៅក្រមស៊ើបអង្កេតទាល់តែសោះ ។

---

*Barayagwiza, សំណុំរឿងលេខ* ICTR-97-19-AR72-របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ ICTY ចុះថ្ងៃទី៣ខែវិច្ឆិកាឆ្នាំ១៩៩៩ កឋាខណ្ឌទី៧៤-៧៧។

[65] *សភាពការណ៍នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោនៅក្នុងករណីរឿងក្តី រដ្ឋអាជ្ញាទល់នឹង Thomas Lubanga Dyilo, សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់លោក* Thomas Lubanga Dyilo ប្រឆាំងចំពោះសេចក្តីសំរេចអំពីការតវ៉ារបស់មេធាវី អំពីយុត្តាធិការរបស់តុលាការ អនុលោមតាមមាត្រា ១៩(២)(ក)នៃលក្ខន្តិកៈ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦-សំណុំរឿងលេខ 01/04-01/06 (OA4) របស់អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១៤ ធ្នូ ២០០៦, កឋាខណ្ឌទី៤២ ។

៨២. អ.វ.ត.ក បានអនុវត្តសកម្មភាពយ៉ាងត្រឹមត្រូវ តាមច្បាប់និងវិធានផ្ទៃក្នុងរបស់ខ្លួន ។ អង្គជំនុំជម្រះនេះមិនដែលបានធ្វើសកម្មភាពដោយមានការព្រមព្រៀងគ្នា ឬបានឱ្យសច្ចានុម័ត ឬផ្តល់សុពលភាពដល់សកម្មភាពរបស់តុលាការយោធាទាល់តែសោះ ។ ហេតុនេះ អ.វ.ត.ក មិនអាចត្រូវដាក់ឱ្យទទួលខុសត្រូវ ចំពោះសកម្មភាពរបស់អង្គភាពតុលាការផ្សេងដាច់ដោយឡែក ពីគ្នានោះបានទេ ។ ដូច្នេះ ការរំលោភបំពាន បែបទាំងនោះ ដែលអាចមានទៅលើសិទ្ធិរបស់ជនត្រូវចោទ គឺមិនមែនជាកំហុសរបស់ អ.វ.ត.ក នោះទេ ។

៨៣. ជាទីបញ្ចប់ មេធាវីការពារក្តីមិនបានបញ្ជាក់បង្ហាញអំពីថា តើពួកគេធ្លាប់បានធ្វើបណ្តឹងឧទ្ធរណ៍ តវ៉ាអំពីការចេញដីកាឱ្យឃុំខ្លួនជាបន្តបន្ទាប់របស់តុលាការយោធាដែរឬទេ ហើយតើបានដល់កំរិតណាហើយ ។ គឺវាហាក់ដូចជាជនត្រូវចោទត្រូវបានតំណាងដោយមេធាវីការពារក្តីដដែលៗ នៅក្នុងដំណើរការនីតិវិធីទាំងមូល នៅក្នុងតុលាការយោធា ។ សហព្រះរាជអាជ្ញាសូមស្នើដាក់ជូនថា អង្គបុរេជំនុំជម្រះគួរតែពិនិត្យអំពីកំរិតដែលការស្នើសុំដំណោះស្រាយរបស់ជនត្រូវចោទ ដែលបានត្រូវផុតរលត់អស់ក្នុងការប្តឹងឧទ្ធរណ៍ ចំពោះមុខតុលាការយោធា បើប្រសិនជាជននេះត្រូវពោលអះអាងថា អ.វ.ត.ក ដែលជាអង្គជំនុំជម្រះមួយមានយុត្តាធិការផ្សេងដាច់ដោយឡែកនោះ ត្រូវតែផ្តល់ឱ្យនូវដំណោះស្រាយដោយខ្លួនឯងចំពោះការរំលោភបំពាននៅក្នុងតុលាការយោធា ។

## *ផ្នែកទី II*

## គ្មានមូលដ្ឋានដែលនៅសេសសល់ដើម្បីផ្តល់ជាដំណោះស្រាយអ្វីមួយឱ្យជនត្រូវចោទទេ

៨៤. សហព្រះរាជអាជ្ញា សូមគាំទ្រចំពោះការលើកហេតុផលមកសំអាងរបស់ សហចៅក្រមស៊ើបអង្កេតដែលប្រកាន់យកថា មិនមានមូលដ្ឋានដែលនៅសេសសល់សំរាប់ផ្តល់នូវដំណោះស្រាយឱ្យជនត្រូវចោទនោះទេដោយផ្អែកលើទឡ្ហីករណ៍ដូចតទៅ[66]៖

---

[66] កថាខណ្ឌទី២១ ។

00154598



(i) ការឃុំខ្លួនជនត្រូវចោទដែលអូសបន្លាយពេលយូរនៅក្រោមយុត្តាធិការរបស់តុលាការយោធាមិនអាចបានចាត់ទុកថាមានលក្ខណៈគ្រប់គ្រាន់ជាការរំលោភបំពានធ្ងន់ធ្ងរចំពោះសិទ្ធិរបស់ជនត្រូវចោទដែលតម្រូវឱ្យមានដំណោះស្រាយជាបន្ទាន់នោះបានទេ ។ ហើយ

(ii) ដំណោះស្រាយណាមួយជាយថាហេតុសំរាប់ការឃុំខ្លួនបែបនេះគឺមិនមែនជាបញ្ហាដែលត្រូវលើកក្នុងកំឡុងពេលដំណើរការនីតិវិធីស៊ើបសួរនោះទេ ។

<u>(i) ការឃុំខ្លួនដោយអូសបន្លាយពេលយូរ</u>

<u>មិនមានលក្ខណៈគ្រប់គ្រាន់ដែលត្រូវចាត់ទុកថាជាការរំលោភធ្ងន់ធ្ងរទេ</u>

៨៥. អវត្តមាននៃមានទំនាក់ទំនងជាផ្លូវការណាមួយរវាងតុលាការអន្តរជាតិឯករាជ្យ និង តុលាការជាតិ ព្រមទាំងអវត្តមាននៃ "ការព្រមព្រៀងរួមគ្នាធ្វើសកម្មភាព" រវាងតុលាការទាំងនោះដែលតុលាការអន្តរជាតិណាមួយ (ហើយហេតុដូច្នេះក៏ជា តុលាការអន្តរជាតូបនីយកម្មណាមួយដែរ) អាចយកមកធ្វើជាមូលដ្ឋាន ក្នុងការផ្តល់នូវដំណោះស្រាយមួយចំពោះការរំលោភបំពានលើសិទ្ធិរបស់ជនសង្ស័យនៅចំពោះមុខតុលាការយោធានោះ គឺត្រូវបានកំរិតកំណត់យ៉ាងតឹងតែង ។

៨៦. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងករណីរឿងក្តីរបស់ *Thomas Lubanga* Dyilo[67] បានបញ្ជាក់អះអាងថា ការវិនិច្ឆ័យរបស់អង្គបុរេជំនុំជម្រះរបស់ខ្លួនដែលបានថ្លែងថា ការផ្តល់នូវការធានារ៉ាប់រងបន្ថែមអំពីសិទ្ធិរបស់ជនសង្ស័យនោះគឺ: "ត្រូវជាប់ក្នុងរង្វង់ដំណាក់ការនៃការធ្វើទារុណកម្ម ឬប្រព្រឹត្តកម្ម ដ៏ធ្ងន់ធ្ងរដោយអាជ្ញាធរជាតិនៃរដ្ឋដែលជាអាណាព្យាបាល តាមបែបណាមួយទាក់ទងទៅនឹងដំណើរការក្នុងការចាប់ខ្លួន

[67] *សភាពការណ៍នៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោនៅក្នុងករណីរឿងក្តី រដ្ឋអាជ្ញាទល់នឹង Thomas Lubanga Dyilo, សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់លោក* Thomas Lubanga Dyilo ប្រឆាំងចំពោះសេចក្តីសំរេចអំពីការតវ៉ារបស់មេធាវី អំពីយុត្តាធិការរបស់តុលាការ អនុលោមតាមមាត្រា ១៩(២)(ក)នៃលក្ខន្តិកៈ ចុះថ្ងៃទី៣ តុលា ២០០៦-សំណុំរឿងលេខ 01/04-01/06 (OA4) របស់អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១៤ ធ្នូ ២០០៦, កថាខណ្ឌទី៤០ ។

00154599



និងការបញ្ជូនខ្លួនជននោះទៅឱ្យតុលាការអន្តរជាតិ ដែលពាក់ព័ន្ធ"[68] ។

៨៧. មេធាវីបានពោលអះអាងថា មានការបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់ជនត្រូវចោទ ដែលត្រូវទទួលការជំនុំជម្រះក្នុងពេលវេលាមួយដ៏សមស្រប ។ ពួកគេបានពឹងផ្អែកយ៉ាងខ្លាំងទៅលើយុត្តិសាស្ត្ររបស់តុលាការ ECHR និងទៅលើឯកសារយោងរបស់គណៈកម្មាធិការសិទ្ធិមនុស្ស(HRC) ។ ករណីរឿងទាំងអស់នេះគឺសំរាប់ដោះស្រាយចំពោះបទល្មើសព្រហ្មទណ្ឌសាមញ្ញ "ជាតិ" ។ គ្មានករណីណាមួយ ដែលទាក់ទងទៅនឹងការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ឬច្បាប់ព្រហ្មទណ្ឌអន្តរជាតិទេ ។ ការដែលមេធាវីផ្អែកទៅលើករណីរឿងក្តីទាំងនេះហាក់ដូចជាពឹងផ្អែកយ៉ាងខ្លាំងទៅលើសំដីពោលអះអាងជាក់លាក់ ដោយបញ្ឆិតបញ្ឆៀងថា ដំណើរការនីតិវិធីរបស់ អ.វ.ត.ក គឺជាការបន្តដំណើរការនីតិវិធីរបស់តុលាការយោធា ។ ដូចដែលបានដាក់ជូនរួចមកហើយ តាមពិតគឺមិនមានការធ្វើបន្តអ្វីនោះទេ ។

៨៨. ការដកស្រង់សំដីរបស់ អ.វ.ត.ក ពីករណីផ្សេងៗរបស់តុលាការECHR និងគណៈកម្មាធិការសិទ្ធិមនុស្ស (HRC) ដែលបញ្ជាក់បំភ្លឺឱ្យឃើញច្បាស់ថាការឃុំខ្លួនមុនពេលជំនុំជម្រះហួសកំណត់ គឺជាការមិនត្រឹមត្រូវតាមច្បាប់ទេអនុលោមតាមបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិត្រូវទទួលការជំនំជុំម្រះក្តីនៅក្នុងពេលវេលាមួយដ៏សមស្រប ។ អត្ថិភាពនៃបទដ្ឋានអន្តរជាតិនេះគឺមិនថិតនៅក្នុងការវិវាទទេ។ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាចោទសួរអំពីការពាក់ព័ន្ធនៃយុត្តាធិការនេះទៅនឹងកាលៈទេសៈដោយឡែកនៃករណីរឿងក្តីរបស់ជនត្រូវចោទ ។ ផ្ទុយទៅវិញយុត្តិសាស្ត្រមកពីតុលាការអន្តរជាតិ ឬតុលាការដែលត្រូវបានធ្វើអន្តរជាតូបនីយកម្មនានា គឺជួយបានច្រើនជាងនេះឆ្ងាយណាស់[69] ដែលជាការបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា នៅក្នុង

---

[68] *សភាពការណ៍នៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោនៅក្នុងករណីរឿងក្តី រដ្ឋអាជ្ញាទល់នឹង Thomas Lubanga Dyilo, សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់លោក* Thomas Lubanga Dyilo ប្រឆាំងចំពោះសេចក្តីសំរេចអំពីការតវ៉ារបស់មេធាវី អំពីយុត្តាធិការរបស់តុលាការ អនុលោមតាមមាត្រា ១៩(២)(ក)នៃលក្ខន្តិកៈ ចុះថ្ងៃទី៣ តុលា ២០០៦-សំណុំរឿងលេខ 01/04-01/06 របស់អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី៣ តុលា ២០០៦, ទំព័រទី១០ ។

[69] *សភាពការណ៍នៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោនៅក្នុងករណីរឿងក្តី រដ្ឋអាជ្ញាទល់នឹង Thomas Lubanga Dyilo,* សេចក្តីសំរេចលើការតវ៉ារបស់មេធាវីអំពីយុត្តាធិការរបស់តុលាការអនុលោមតាមមាត្រា ១៩(ក)នៃលក្ខន្តិកៈ សំណុំរឿងលេខ01/04-01/06, របស់អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី៣ តុលា ២០០៦, ទំព័រទី១០ ដោយធ្វើការប្រៀបធៀបបញ្ចូលគ្នាចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងការឃុំខ្លួនបណ្តោះអាសន្ន លើឈ្មោះ ឌុច

យុត្តិសាស្ត្រទាំងនោះចង្អុលបង្ហាញថា មានតែនៅទីកន្លែងដែលមានភស្តុតាងអំពីអំពើទារុណកម្ម ឬប្រព្រឹត្តកម្មធ្ងន់ធ្ងរបានកើតឡើងតែប៉ុណ្ណោះ ដែលតុលាការដែលត្រូវជំនុំជម្រះក្តីលើបទឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរផ្សេងៗ ត្រូវផ្តល់នូវដំណោះស្រាយជាបន្ទាន់លើការរំលោភបំពានដែលបានកើតមានកាលពីនៅក្នុងតុលាការជាតិ ។

៨៩. មេធាវីការពារក្តី មិនបានលើកឡើងថា ជនត្រូវចោទត្រូវបានគេដាក់ឱ្យទទួលរងនូវទារុណកម្ម ឬ រងនូវការឃុំគ្រងមិនត្រឹមត្រូវយ៉ាងធ្ងន់ធ្ងរ ក្នុងកំឡុងពេលនៃការឃុំខ្លួនដោយតុលាការយោធាទេ ទុកបណ្តឹងណាមួយបែបដូច្នេះឱ្យមានការជាប់ពាក់ព័ន្ធដោយឯកឯង ទៅនឹងដំណើរការចាប់ និងបញ្ជូនខ្លួនទៅឱ្យ អ.វ.ត.ក ។

៩០. ដោយសារតែមិនមានភស្តុតាង ស្តីពីមានការធ្វើទារុណកម្ម ឬ ការឃុំគ្រងមិនត្រឹមត្រូវយ៉ាងធ្ងន់ធ្ងរណាមួយបែបនោះ បើសិនជាមូលហេតុស្តីពីការឃុំខ្លួនជាបណ្តោះអាសន្នត្រូវបានបំពេញហើយក៏ដោយក៏អវតក មិនមានមូលដ្ឋានដើម្បីនឹងចេញដីកាដោះលែងជនត្រូវចោទចេញពីការឃុំខ្លួនបណ្តោះអាសន្នបានដែរ។

<u>(ii) មិនមានដំណោះស្រាយអ្វីសំរាប់ការរំលោភបំពាន ដែលមានលក្ខណៈស្រាលជាងនៅក្នុងដំណាក់កាលនៃការស៊ើបសួរទេ</u>

៩១. នៅពីមុខសំណុំឯកសារ សហព្រះរាជអាជ្ញាមិនមែនមិនយល់ព្រមថា ការឃុំខ្លួនរបស់ជនត្រូវចោទនៅចំពោះមុខតុលាការយោធាអាចនឹងងាយមានបញ្ហាណាស់ ផ្អែកតាមទស្សនៈនៃបទដ្ឋានយុត្តិធម៍អន្តរជាតិ។ ក៏ប៉ុន្តែដូចដែលបានពិភាក្សារួចមកហើយ ដំណោះស្រាយដោយ

---

ជាមួយករណីរឿងរបស់ រដ្ឋអាជ្ញាទល់នឹង *Dragan Nikolic, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្គំ ពីនីត្យានុកូលភាពនៃការចាប់ខ្លួន របស់សាលាឧទ្ធរណ៍នៃតុលាការ* ICTY៖ សំណុំរឿងលេខ IT-94-2-AR73, *ចុះថ្ងៃទី៥ មិថុនា ២០០៣ ។ និងក្នុងករណីរឿងក្តីរបស់ រដ្ឋអាជ្ញាទល់នឹង Jean Bosco Barayagwiza, សំណុំរឿងលេខ* ICTR-97-19-AR72, នៃសាលាឧទ្ធរណ៍ - ចុះថ្ងៃទី៣ វិច្ឆិកា ១៩៩៩ ។

ការដោះលែងជាបន្ទាន់ គឺមិនមានសំរាប់ឲ្យ អវតក ធ្វើនោះទេ។ ទោះជាយ៉ាងណាក្តីក៏អាចនឹងមានកាលៈទេសៈខ្លះដោយមានការកំរិតកំណត់ ដែលក្នុងនោះជនត្រូវចោទអាចនឹងត្រូវផ្តល់នូវដំណោះស្រាយ ។

៩២. មានការលើកធ្វើនៅចំពោះមុខតុលាការអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវី[70]ថាការរំលោភផ្សេងៗលើសិទ្ធិរបស់ជនជាប់ចោទដែលឥតមានការធ្វើទារុណកម្ម ឬប្រព្រឹត្តកម្មធ្ងន់ធ្ងរ អាចបណ្តាលឱ្យមានដំណោះស្រាយផ្សេងៗនៅពេលធ្វើសេចក្តីសន្និដ្ឋានក្នុងពេលជំនុំជម្រះក្តី ។ នេះគឺអាច នឹងរួមបញ្ចូលទាំងការសងជម្ងឺចិត្តជាលុយកាក់ផង នៅក្នុងករណីបើត្រូវគេធ្វើការលើកលែងការចោទប្រកាន់ ឬ បន្ធូរបន្ថយទោស ក្នុងករណីបើសិនជាត្រូវមានទោស[71]។

៩៣. ដំណោះស្រាយផ្សេងៗបែបដូចនេះគឺអាស្រ័យទាំងស្រុងទៅលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។ទាំងសហចៅក្រមស៊ើបអង្កេតទាំងអង្គបុរេជំនុំជម្រះមិនអាចត្រូវជាប់កាតព្វកិច្ចប្រតិបត្តិតាមលើបញ្ញត្តិពីឆន្ទានុសិទ្ធក្នុងការផ្តល់នូវដំណោះស្រាយដែលសហចៅក្រមស៊ើបអង្កេតបានប្រតិបត្តិតាមយ៉ាងត្រឹមត្រូវ"គឺវាមិនមែនជាបញ្ហានៅក្នុងដំណាក់កាលនៃការស៊ើបសួរនោះទេ"[72] ។

---

[70] ករណីរឿងក្តី រដ្ឋអាជ្ញាទល់នឹង *Jean Bosco Barayagwiza* ។ សំណើរបស់រដ្ឋអាជ្ញាឱ្យធ្វើការពិនិត្យសារឡើងវិញ ឬពិនិត្យពិចារណាឡើងវិញ-សំណុំរឿងលេខ ICTR-97-19-AR72, របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ ICTR, ចុះថ្ងៃទី៣១ មីនា ២០០០។

[71] តុលាការដែលកាត់ឱ្យមានទោសនៅក្នុងករណីរឿងរបស់ Barayagwisa ដែលតមកទៀតអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានធ្វើការពិនិត្យឡើងវិញនូវសេចក្តីសំរេចដោយកាត់បន្ថយទោសរបស់ជនជាប់ចោទក្រោយពីជននេះត្រូវកាត់ឱ្យមានទោស ដោយគិតរាប់បញ្ចូលទាំងរយៈពេលដែលបានជាប់រួចហើយពីមុនមកក្នុងកន្លែងឃុំឃាំងរបស់យុត្តាធិការក្នុងស្រុកផង ។ សូមអាន ករណីរឿងក្តី រដ្ឋអាជ្ញាទល់នឹង *Jean Bosco Barayagwiza* –សាលក្រមនិងការសំរេចកាត់ឱ្យជាប់ទោស-សំណុំរឿងលេខ ICTR-99-52-T របស់សាលាដំបូងនៃ តុលាការ ICTR, ចុះថ្ងៃទី៣ ធ្នូ ២០០៣ ។

[72] ដីកាសំរេចឲ្យឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣១ មិនា ២០០០, កថាខណ្ឌទី២១ ។

**សំណើ**

៩៤. ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យ អង្គបុរេជំនុំជម្រះ **បដិសេធទាំងស្រុង** លើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី លើកលែងតែ សំណើសុំឲ្យធ្វើសវនាការផ្ទាល់មាត់ជាសាធារណៈ តែប៉ុណ្ណោះ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៧

**ជ. សហព្រះរាជអាជ្ញា**

**លោក យ៉េត ចរិយា** — សហព្រះរាជអាជ្ញារង

**លោក** William SMITH — សហព្រះរាជអាជ្ញារង

00154603

**APPENDICES A-L Not Available in Khmer**